ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ទិវានារីអន្តរជាតិ - ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ
- ពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

ត្រីមាសទី១ ខែមករា ដល់ មីនា ឆ្នាំ២០២២

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

ត្រីមាសទី១ ខែមករា ដល់ មីនា ឆ្នាំ២០២២

## មាតិកា

### សំបុត្រ


- អន្ទង់វែងស្នេហា ............................ ១
- គំនិតផ្ដួចផ្ដើមនៃការងារស្ម័គ្រចិត្ត .......... ២
- ទិវានារីអន្តរជាតិ - ព្រះមហាក្សត្រី ......... ៣


### ផ្នែកឯកសារ


- សូ គីមអាន ហៅ អាចារ្យ ម៉ី អនុលេខា .... ៥
- គុយ យ៉ុន គណៈយោធាស្រុកត្របែក ...... ៩
- សោម ពៅ៖ លេខាសង្កាត់បន្ទាយចក្រី .. ១២


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ម៉ម រិន៖ ខ្មែរក្រហមធ្វើឲ្យស្ពានភាព...... ១៥
- ពិធីសម្ពោធចេតីយ៍រំឭកវិញ្ញាណក្ខន្ធ........ ២០
- សឿ ណាន៖ ពិការជើងដោយសារ ...... ២៥
- ឯកអគ្គរដ្ឋទូតហ៊ីលីពីនទស្សនកិច្ច....... ២៧
- រឿងរ៉ាវរបស់ ឯម ម៉ឺ ក្នុងរបប ........... ៣០
- ឯកអគ្គរដ្ឋទូតសិង្ហបុរីទស្សនកិច្ចតំបន់ ...៣៤
- ដំណើរទស្សនកិច្ចរួមគ្នារបស់ឯកអគ្គ.... ៣៨
- កិច្ចពិភាក្សារវាងមជ្ឈមណ្ឌលឯកសារ ...៤៣
- ឈន ខិន្នែត ៖ ខ្មែរក្រហមយកឪពុកខ្ញុំ....៤៥
- ថៃ ថាត ៖ ខ្មែរក្រហមសម្លាប់ក្រុម ...... ៤៧
- ធីក ង៉ែត៖ កងនារីស្រែអំបិល ........... ៤៩
- អ៊ាប ម៉ុង ៖ កងចល័តស្រុកព្រែកប្បាស... ៥១
- ឪពុករបស់ខ្ញុំស្លាប់ដោយសារលួចដំឡូង..៥៣


### ផ្នែកវេទិកាសាធារណៈ


- តើលោកអាចកំណត់អ្នករស់រានមានជីវិត... ៥៦


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- ស្វែងរកសមាជិកគ្រួសារ៦នាក់ ដែលបាត់ខ្លួនតាំងពីឆ្នាំ ១៩៧៣ ....................... ៥៨
- បងប្រុសរបស់ខ្ញុំដែលបាត់ខ្លួន ........... ៥៩
- ខ្ញុំសូមប្រកាសរកបងប្រុសដែលបាត់ខ្លួន..៦០




រូបថតចាស់ៗដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្ដល់ឲ្យក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាពេលចុះទៅធ្វើការនៅតាមតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, ដារ៉ារដ្ឋ មេត្តា, ភា រស្មី, ទូច វណ្ណេត, ង៉ាន់ វីន, មេក វិន, ឈុំ រ៉ា, គីម សុវណ្ណដានី, សៀង កញ្ញា, ហៀក ស្រីពេជ្រ និង មីន សាណាស់

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# អន្លង់វែងស្នេហា

## ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា




*មេខលា រាំនៅខាងមុខ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង តំណាងឲ្យសន្តិភាព ដែលមាននៅក្នុងបទចម្រៀងអន្លង់វែងស្នេហា។ (បណ្ណសារ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

I. ឳ អន្លង់វែង ជាទេពនិម្មិត ស្ថិតក្នុងកែវភ្នែក ជាប់សម្រស់ខ្នងភ្នំដងរែក បេះដូងខ្ញុំប្លែកខុសពីធម្មតា
ចិត្តធ្លាប់អង់អាច បែរជាចុះចាញ់ សម្រស់បុប្ផា បេះដូងវាយពាក្យស្នេហា តាមកែវនេត្រាតើអូនដឹងទេ?

II. មើលហ្វូងពពក រសាត់រត់មកលើចុងព្រឹក្សា ស្រមៃដូច ភក្ត្រស្ងួនដី៏រ៉ា ញញឹមពព្រាយប្រាប់បងថាស្នេហ៍
គឺជាឱសថ លាងស្នាមជូរចត់ ទុក្ខាលែងក្បែរ អន្លង់វែងអន្លង់ក្ដីស្នេហ៍ ទោះរយឆ្នាំខែបងនៅតែចាំ។

R. ពេលយប់សួរផ្កាយ ពេលថ្ងៃបងសួរព្រៃព្រឹក្ស ពយតាម៉ុកអ័ព្ទធ្លាក់សន្ទឹកក្ដីស្នេហ៍ឲ្យទឹក ទាំងចិត្តប្រេះស្រាំ
ឃើញឥន្ទធនូ បងឈរមើលយូរ មិនស្ដៀបរការ តែស្នេហ៍យើងមានរបាំង បេះដូងបងស្រាំគ្មានសល់អ្វី។

III. កុំដូចពពក ហិចហើរទៅមក គង់ក្លាយជាភ្លៀង វាសនា ប្រែប្រួលមិនទៀង ពពកជាភ្លៀង ភ្លៀងធ្លាក់
ដល់ដីឳ អន្លង់វែង មានភ្នំដងរែកជម្រកក្ដី ចម្លងនូវក្ដីស្រមៃ ឲ្យមាននិស្ស័យជាគូវាសនា។

និពន្ធទំនុកច្រៀង និងបទភ្លេងដោយ ៖ **ស៊ុំ សារឿន**

រក្សាសិទ្ធិដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០២២

# គំនិតផ្តួចផ្តើមនៃការងារស្ម័គ្រចិត្ត

ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា







អ្នកស្ម័គ្រចិត្តកម្ពុជា ជួបជាមួយចាស់ទុំដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា ជ្រើសរើសយកគំនិតផ្តួចផ្តើមនៃការងារស្ម័គ្រចិត្តហៅថា ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ជាផ្នែកនៃកិច្ចខិតខំ ប្រឹងប្រែងដើម្បីកសាងនិរន្តរភាពនៅក្នុងគម្រោងរបស់យើង ដើម្បីគាំទ្រសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាគឺ ជាកម្មវិធីសេវាកម្មស្ម័គ្រចិត្តរបស់យុវវ័យ សម្របសម្រួលដោយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការផ្តល់ការ គាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ គំនិតផ្តួចផ្តើមនេះគឺយកគំរូពីក្រុមអ្នកស្ម័គ្រចិត្តរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក។ សេវាកម្មអ្នកស្ម័គ្រចិត្តនេះនឹងរួមបញ្ចូលអ្នកស្ម័គ្រចិត្តចំនួន ៨០០នាក់មកពី២៥ខេត្តក្រុងនៃប្រទេសកម្ពុជា។ គោលបំណងនៃ គំនិតផ្តួចផ្តើមនេះគឺដើម្បីធ្វើឲ្យអ្នកស្ម័គ្រចិត្តម្នាក់ៗសម្របខ្លួននិងធ្វើការជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងគោលបំណង ផ្តល់ជំនួយជាបុគ្គលដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា គឺមានលក្ខណៈពិសេសមិនត្រឹមតែជួយ ឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបានជំនួយជាបុគ្គលតែប៉ុណ្ណោះទេ អ្នកស្ម័គ្រចិត្តអាចជួយឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យទទួលបានការថែរក្សាសុខភាព ហើយយុវជនស្ម័គ្រចិត្តផ្ទាល់នឹងទទួលបានអត្ថប្រយោជន៍និងឱកាសរៀនសូត្រពី អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម លើលពីនេះទៅទៀតដើម្បីបង្ហាញអំពីសេវាកម្មសង្គម ភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្តចំពោះប្រទេសជាតិកម្ពុជា។

# ទិវានារីអន្តរជាតិ - ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ

ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា




*សៀវភៅ «**សាក្សីប្រវត្តិសាស្ត្រ** ៖ សៀវភៅកំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ»។ សៀវភៅកំណត់ហេតុរបស់សម្តេចព្រះវររាជមាតាជាតិខ្មែរ ត្រូវបានបកប្រែពីភាសាបារាំង ដោយលោកឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ អេ. ហែលជ្រេស ដែលបានបំពេញតួនាទីជាលេខាផ្ទាល់ជាន់ខ្ពស់របស់សម្តេចព្រះបរមរតនកោដ្ឋ ប្រមាណជាង១២ឆ្នាំ។ សៀវភៅកំណត់ហេតុនេះ បោះពុម្ពឡើងដោយគម្រោងស្រាវជ្រាវភាសាចិនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី៨ ខែមីនាជារៀងរាល់ឆ្នាំ ទិវានារីអន្តរជាតិ គឺជាថ្ងៃដ៏វិសេសវិសាលបំផុតមួយ ដែលត្រូវបានប្រារព្ធឡើងដើម្បីអបអរដល់សមិទ្ធផលរបស់ស្ត្រី បង្កើនការយល់ដឹងអំពីសមភាពរបស់ស្ត្រី និងជំរុញសមភាពយេនឌ័រ ឲ្យកាន់តែប្រសើរឡើង។ ថ្ងៃនេះ ខ្ញុំសូមថ្វាយសម្តេចម៉ែនូវព្រះកិត្តិយស បំពោះ

ការបំពេញព្រះរាជកិច្ចដោយឥតនឿយណាយរបស់ព្រះអង្គ សម្រាប់ប្រជាជនកម្ពុជា ទាំងអស់។ ព្រះរាជដំណើរជីវិតមួយផ្នែកនៃព្រះអង្គ ត្រូវបានពិពណ៌នា នៅក្នុងសៀវភៅ **សាក្សីប្រវត្តិសាស្ត្រ** ។ ក្នុងព្រះនាមជាព្រះរាជវរមាតាជាតិខ្មែរ ព្រះមហាក្សត្រី គឺជាព្រះរាជសាក្សីនៃជំពូកជាច្រើនរបស់ប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ តាមរយៈប្រវត្តិសាស្ត្រនេះ ព្រះអង្គបានបំពេញព្រះរាជកិច្ចទាំងនៅលើឆាកជាតិនិងអន្តរជាតិ ព្រមទាំងព្រះរាជកិច្ចសំខាន់ៗជាច្រើនដែលមិនសូវដឹងឮ ដើម្បីទ្រទ្រង់ដល់ប្រជាជនកម្ពុជា ទាំងអស់។ ឆ្លៀតឱកាសនៅក្នុងថ្ងៃដែលទទួលស្គាល់ចំពោះតម្លៃ ក៏ដូចជាលើកកម្ពស់សិទ្ធិរបស់ស្ត្រីទាំងអស់ ខ្ញុំសូមថ្វាយព្រះកិត្តិយស សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ដែលជាវីរស្ត្រីមួយព្រះអង្គ នៃស្ត្រីគ្រប់រូបនិងជនរួមជាតិកម្ពុជា ទាំងអស់។



ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ យាងទស្សនកិច្ចប្រាសាទបន្ទាយស្រី ក្នុងខេត្តសៀមរាប នៅឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ គង់លើអង្រឹងសរសេរ កំណត់ហេតុក្នុងព្រះរាជដំណើរយាងមកកាន់តំបន់រំដោះក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សូ គឹមអាន ហៅ អាចារ្យ មុី អនុលេខា តំបន់ ១០៥ ភូមិភាគឦសាន

*ដារ៉ាវឌ្ឍ មេត្តា*



កងឈ្លបបដិវត្តន៍ខ្មែរក្រហមកំពុងដោតចម្រូងការពារភូមិ។ ខេត្តរតនគិរី ឆ្នាំ១៩៦៨-១៩៦៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សូ គឹមអាន ហៅ អាចារ្យ មុី មានអាយុ ៤៤ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧)។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រែកអ្នកលឿង ឃុំព្រែកអ្នកលឿង ស្រុកពាមរក៍ តំបន់២៤។ នៅក្នុងឆ្នាំ១៩៥៤ ខ្ញុំប្រឡងជាប់សាលាបាលីជាន់ខ្ពស់។ កាលខ្ញុំនៅរៀនខ្ញុំស្នាក់នៅ

កុដិលោកអាចារ្យ ឃុត មានសញ្ញារូបសេះ នៅវត្តខណ្ឌលោម។ ខ្ញុំមានភាពជិតស្និទ្ធជាមួយអាចារ្យ ឃុត ក្រោយមកប្រហែលជាចុងឆ្នាំ១៩៥៨ ខ្ញុំចូលជាខ្មែរសេរី។

នៅក្នុងឆ្នាំ១៩៥៨ ខ្ញុំត្រូវប្រឡងសញ្ញាបត្រមធ្យមសិក្សាដូច្នេះខ្ញុំត្រូវតែខិតខំរៀនដើម្បីត្រៀមប្រឡង។ ខ្ញុំទាក់ទងសិស្សម្នាក់ឈ្មោះ ញេប សាវ៉ាន រស់នៅភូមិព្រែកអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង ដោយអប់រំនយោបាយក្បត់និងប្រគល់ឲ្យអាចារ្យ ឃុត អប់រំបន្តរួចហើយ ចាត់តាំង សាវ៉ានជាសមាជិកខ្មែរសេរី។ ក្រោយមកខ្ញុំប្រឡងធ្លាក់ និងត្រូវរៀនរយៈពេល១ឆ្នាំថែមទៀត។ បន្ទាប់មកខ្ញុំក៏ប្រឡងជាប់ហើយក៏ឈប់រៀន។

នៅក្នុងឆ្នាំ១៩៥៩ គ្រូបង្រៀនឈ្មោះ ជ័យ អេ គឺជាខ្មែរសេរីបង្រៀននៅសាលាបឋមសិក្សារំលង ខេត្តកំពង់ធំបានបើកសាលាឈ្នួលឈ្មោះ អនុវិទ្យា-ល័យសង្គមសិក្សា នៅក្រុងកំពង់ធំ។ ជ័យ អេ មកទាក់ទងអាចារ្យ សាន វត្តសារាវ័ន ក្រុងភ្នំពេញ។ អាចារ្យ សាន បានមកទាក់ទងខ្ញុំ។ ខ្ញុំបង្រៀននៅអនុវិទ្យាល័យសង្គមសិក្សាបានរយៈពេល១ឆ្នាំ ប៉ុន្តែដោយសារខ្ញុំឃើញសាលាមិនមានស្ថិរភាពខ្ញុំបានសុំលា ជ័យ អេ ទៅបង្រៀនជាមួយ យឹម ធន នៅសាលាអនុវិទ្យាល័យវិជ្ជាសោភ័ណ។ នៅក្នុងឆ្នាំ១៩៦៦ និង១៩៦៧ អនុវិទ្យាល័យវិជ្ជាសោភ័ណត្រូវបិទទ្វារឈប់បង្រៀនដោយសារមិនមានសិស្សចូលរៀន និងការចំណាយច្រើនជាងចំណូល។ ខ្ញុំត្រូវផ្អាកការបង្រៀនមួយរយៈ ប៉ុន្តែខ្ញុំនៅតែបន្តសកម្មភាពចូលបង្កប់ខ្លួននៅក្នុងចលនាបដិវត្តន៍និងរស់នៅជាមួយអ្នកបដិវត្តន៍តាមរយៈឈ្មោះ នៅ ផន ហៅ សុក។ នៅ ផន ហៅ សុក បានខទ្វេសនាមមិត្ត ហុង ឲ្យស្គាល់ខ្ញុំ ធ្វើឲ្យខ្ញុំមានឱកាសស្និទ្ធស្នាលជាមួយអ្នកបដិវត្តន៍បន្ថែមទៀត។

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៦៧ ខ្ញុំត្រូវចេញពីកំពង់ធំមកនៅភ្នំពេញដើម្បីចូលបង្កប់ខ្លួនមិនឲ្យអង្គការបដិវត្តន៍ដឹង។ ខ្ញុំទាក់ទងជាមួយ យឹម ធន គឺជាពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលា។ យឹម ធន បានប្រឡងជាប់ពេទ្យនៅក្នុងឆ្នាំ១៩៦២ បន្ទាប់ពីចាកចេញពីខេត្តកំពង់ធំ។ ធន ប្រាប់ខ្ញុំថា គាត់មានមិត្តភក្តិឈ្មោះ ដាវ៉ាល់ ពាក់ស័ក្តិ២ គឺជាគិញនៅក្រសួងនគរបាលជាតិភ្នំពេញ។ យឹម ធនបានឲ្យ ដាវ៉ាល់ រកវិធីសាស្ត្រដើម្បីឲ្យអង្គការបដិវត្តន៍ជឿថា ខ្ញុំគឺជាអ្នកបដិវត្តន៍ប្រាកដមែន។ យឹម ធន ចង់ឲ្យ ដាវ៉ាល់ ចេញសំបុត្រចាប់ខ្លួនគិញដែលលាក់ខ្លួននៅក្នុងក្រុង និងខេត្ត។ ដាវ៉ាល់ គិតថាត្រឹមតែចេញសំបុត្រចាប់ខ្លួនមិនជាក់ស្តែងនោះទេគាត់នឹងបញ្ជូនឲ្យគិញ ៣នាក់ទៅចាប់ខ្លួនខ្ញុំដល់ផ្ទះ។ គិញ តាមចាប់ខ្លួនខ្ញុំចំនួន ២លើក ក្នុងខែកក្កដា និងខែសីហា ប៉ុន្តែចាប់ខ្ញុំមិនបានក៏ទុកសំបុត្រចាប់ខ្លួនឲ្យម្តាយក្មេកខ្ញុំ។

នៅខែកញ្ញា ឆ្នាំ១៩៦៧ អង្គការបដិវត្តន៍ ទិញម៉ាស៊ីនដេរមួយគ្រឿងឧបត្ថម្ភដល់គ្រួសារខ្ញុំ។ ខ្ញុំស្នើអង្គការឲ្យយកម៉ាស៊ីនដេរនោះយកទៅដាក់ដល់ផ្ទះប្រពន្ធរបស់ខ្ញុំនៅកំពង់ធំ។ ខ្ញុំបានទៅផ្ទះហើយម្តាយក្មេកយកសំបុត្រចាប់ខ្លួនមកឲ្យខ្ញុំ។ ខ្ញុំត្រឡប់មកភ្នំពេញវិញ និងយកសំបុត្រនោះឲ្យមិត្តបដិវត្តន៍មើលបន្តគ្នា។ មិត្តផា គឺជាសាស្ត្រចារ្យអនុវិទ្យាល័យស្អាង ប្រាប់ខ្ញុំកុំឲ្យត្រឡប់ទៅផ្ទះវិញទេ គឺត្រូវភៀសខ្លួនទើបរួចផុតពីការចាប់ខ្លួន។ ខ្ញុំត្រូវរស់នៅភ្នំពេញអស់រយៈពេល៣ខែ។ នៅខែតុលា ឆ្នាំ១៩៦៧ ខ្ញុំបានទៅជួបអាចារ្យ ឃុត ដោយបញ្ជាក់ប្រាប់គាត់អំពីដំណើររបស់ខ្ញុំហៀបចាកចេញពីទីក្រុងភ្នំពេញទៅជនបទ។ អាចារ្យ ឃុត ចេញសំបុត្រខទ្វេសនាមឲ្យខ្ញុំមួយសន្លឹកសម្រាប់ទាក់ទង កុយ ធួន។ នៅចុងខែតុលា ឆ្នាំ១៩៦៧ មាននីរសារម្នាក់បាននាំខ្ញុំទៅជួប កុយ ធួន នៅភូមិមួយជិតភូមិបឹងធំ ក្នុងខេត្តកំពង់ចាម។ ខ្ញុំយកសំបុត្រខទ្វេសនាមរបស់អាចារ្យ ឃុត ទៅឲ្យ កុយ ធួន ហើយកុយ ធួន ទទួលស្គាល់ខ្ញុំ។ ខ្ញុំសម្រាកនៅទីនោះបានរយៈពេល២យប់ ខណៈបង កុយ ធួន ជិះទូកឡើងមកទីរួមខេត្តកំពង់ចាម សម្រាក៣យប់ដើម្បីរង់ចាំនីរសាររបស់គាត់ដែរ។ កុយ ធួន អប់រំខ្ញុំថា នៅស្រុកលើមានការលំបាកខ្លាំងណាស់មិត្តត្រូវ

មានការតស៊ូជម្នះ ហើយត្រូវខិតខំអប់រំកម្លាំងក្បត់ឲ្យបានច្រើន។ រយៈពេល៥យប់ ទើបនីសារបានមកដល់ហើយបានណែនាំខ្ញុំឲ្យស្គាល់ឈ្មោះ កង គឺជាខ្មែររបស់គាត់ ហើយ កង ក៏បាននាំខ្ញុំទៅខេត្តមណ្ឌលគិរី។ នៅខែធ្នូ ឆ្នាំ១៩៦៧ ខ្ញុំបានមកដល់ខេត្តមណ្ឌលគិរី។ យើងទៅរស់នៅផ្ទះរបស់ ពូ ឡឺ គឺជាជនជាតិព្នង ក្នុងភូមិពូគ្រេង។ នៅចុងឆ្នាំ១៩៦៨ ខ្ញុំនិងកង បានទៅរៀនវគ្គនយោបាយនៅមន្ទីរក៦០ របស់លេខាតំបន់ ឈ្មោះ ឡាំង។ ខ្ញុំបានជួប កុយ ធួន ហៅ គុន ជួយដឹកនាំការងារតំបន់១០៥ ដែលចល័តជាមួយខេត្តរតនគិរី។



ជនជាតិភាគតិចនៅខេត្តស្ទឹងត្រែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ១៩៦៩ កង និងខ្ញុំបានកែខ្លឹមសារឃោសនាថ្មី ទិសដៅប្រឆាំងជាមួយបដិវត្តន៍។ បដិវត្តន៍វាយមិនឈ្នះចក្រពត្តិអាមេរិក បរិវារភ្នំពេញ និងព្រៃនគរឡើយ។ យើងឃោសនាឲ្យប្រជាជនខ្លាចបដិវត្តន៍មិនហ៊ានចូលព្រៃរកត្រីសាច់ដូចមុន ព្រោះខ្លាចខ្មែរក្រហមចាប់ខ្លួន។ នៅចុងឆ្នាំ១៩៧៨ បង ឡាំង ហៅខ្ញុំទៅរៀននៅមន្ទីររបស់គាត់ ដោយមានឈ្មោះ គុណ គឺជាអ្នកខទ្ទេសនាមឯកសារ។ អ្នកដែលចូលរៀននៅពេលនោះមានបង ឡាំង បងសូរុន បងខាំភូន និងខ្ញុំ។ បន្ទាប់ពីរៀនរួចឈ្មោះ គុណ ហៅខ្ញុំជួបដោយឡែកនិងអប់រំអំពីនយោបាយ។

នៅឆ្នាំ១៩៧០ អង្គការតំបន់១០៥ សម្រេចដកខ្ញុំចេញពីភូមិពូគ្រេងឲ្យទៅធ្វើជាលេខាស្រុកច្បារ ហើយកង ត្រូវ គុណ ដកចេញពីតំបន់១០៥។ មុនពេលបែកគ្នា កង ធ្វើសំបុត្រខទ្ទេសនាមឲ្យខ្ញុំទៅជួបខ្មែរក្បត់នៅស្រែធំឈ្មោះ គ្រូគុំ ដែលបង្កប់ធ្វើសកម្មភាពនៅមូលដ្ឋានស្រែធំ និងប្រគល់សមាជិកក្បត់ទាំង៤នាក់ឲ្យខ្ញុំគ្រប់គ្រង។ នៅពេលនោះខ្ញុំធ្វើជាលេខាស្រុក និងមិត្តចាំ ធ្វើជាអនុលេខា ខណៈដែលខេត្តមណ្ឌលគិរីទាំងមូលត្រូវបានរំដោះ។ ប្រជាជននៅក្នុងស្រុកច្បារ ធ្វើបដិវត្តន៍ មានជំនឿលើបដិវត្តន៍ ពួកគេមិនជឿលើការឃោសនារបស់ខ្មែរសេរីទេ លើកលែងតែពួករដ្ឋការចាស់ និងទាហានប៉ូលីស។

នៅក្នុងឆ្នាំ១៩៧១ អង្គការតំបន់ចាត់តាំងខ្ញុំទៅរៀនសាលាបក្សជាមួយ បងសូរុន បងខាំភូន និងបង ឡាំង ចំនួន២៥ថ្ងៃ។ ពេលនោះខ្ញុំបានជួប ធុច ក្រោយពេលរៀនចប់ ហើយ ធុច បានអប់រំខ្ញុំបន្ថែមទៀត។

នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំត្រូវអង្គការតំបន់១០៥ សម្រេចឲ្យចុះជួយ ផ្តល់យោបល់ ទាក់ទងការងារនៅស្រុកច្បារ អូរាំង និង កែវសីមា រយៈពេល១ខែ។ ខ្ញុំចុះដល់ស្រុកកែវសីមា ជួបជាមួយ កាស៊ី គឺជាលេខស្រុកកែវសីមា បានឲ្យខ្ញុំដឹងសភាពការណ៍នៅស្រុករ៥។ ខ្ញុំបានជូនយោបល់ដល់ កាស៊ី ឲ្យបន្តសកម្មភាពក្បត់ប្រឆាំងបក្សតទៅទៀតតាមសកម្មភាពអាចធ្វើទៅបាន។

នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំជួបជាមួយមេក្រុមក្បត់គ្រប់ក្រុម និងក្តាប់សភាពការណ៍គ្រប់មូលដ្ឋាន ហើយលើក

ទិសដៅការងាររក្សត់ថ្មីតាមសភាពការណ៍ជាក់ស្តែងៗ ឯសភាពការណ៍រួមនៅក្នុងតំបន់គឺមានការចាត់តាំងសហករណ៍កម្រិតទាបជាបន្តបន្ទាប់ ការកើតឡើងបញ្ហាជំទាស់រវាងកម្មសិទ្ធិឯកជន និងសមូហភាព ដោយអ្នកខ្លះចង់ចូលសហករណ៍ អ្នកខ្លះមិនចង់ចូល ហើយមានអ្នកខ្លះទៀតចូលហើយសុំចេញវិញៗ ខ្ញុំបានទាក់ទងឈ្មោះ ប្រាន គឺជាគណៈស្រុក រ២ៗ

នៅក្នុងឆ្នាំ១៩៧៥ សភាពការណ៍នៅក្នុងតំបន់១០៥ មិនមានអ្វីប្រែប្រួលខ្លាំងទេៗ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បដិវត្តន៍ឈ្នះទាំងស្រុកលើចក្រពត្តិអាមេរិក និងបរិវារៗ នៅចុងឆ្នាំ១៩៧៥ ខ្ញុំឡើងមករៀនសាលាបក្សនៅភ្នំពេញ ហើយបានជួបជាមួយ យួនៗ យួនខាងទ្វេសនាមខ្សែរក្សត់ឈ្មោះ យ៉ា ឲ្យខ្ញុំបានស្គាល់ៗ

នៅក្នុងឆ្នាំ១៩៧៦ តំបន់១០៥ ត្រូវចាត់ចូលក្នុងភូមិភាគឦសាន ដោយមានឈ្មោះ យ៉ា គឺជាលេខាភូមិភាគៗ យ៉ា បានទាក់ទងជាមួយខ្ញុំ តាមការខាងទ្វេសនាមរបស់ យួនៗ មុនពេលប្រជុំគណៈតំបន់ យ៉ា បានមកជួបខ្ញុំ អប់រំ និងជំរុញឲ្យកសាងកម្លាំងទាក់ទងជាមួយ យួន ឲ្យបានល្អ និងសម្ងាត់បំផុតៗ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ បងយ៉ា បានឡើងទៅតំបន់១០៥ ប្រជុំគណៈតំបន់ដោយលើកយកបញ្ហាតំបន់មកប្រជុំ រួមមាន ១) បញ្ហាព្រំដែន ២) រៀបចំបោះទីតាំងកងពល និង តំបន់ ៣) ការទាក់ទងកងពល៩២០ និងតំបន់១០៥ ៤) បញ្ហាសហការកងពល និងកងតំបន់ការពារព្រំដែនមណ្ឌលគិរីៗ បញ្ហាព្រំដែន យ៉ា បានបញ្ជាក់ថា ប្រសិនបើមានយួនឈ្លានពានព្រំដែនត្រូវដោះស្រាយដោយសន្តិវិធីគឺចរចាឲ្យយួនដកចេញវិញ និងរាយការណ៍ទៅកាន់ភូមិភាគភ្លាមៗៗ បងយ៉ា មកជួបខ្ញុំដោយឡែកហើយអប់រំខ្ញុំ ពីបញ្ហាព្រំដែនកម្ពុជា និងវៀតណាម ដែលឈានចូលដល់បដិបក្ខខ្ពស់ដោះស្រាយមិនរួចឡើយៗ វៀតណាមមានផែនការនៅក្នុងរដូវប្រាំងវាយយកខេត្តមណ្ឌលគិរី តាមប្រភពព័ត៌មានផ្លូវការសម្ងាត់ពីឈ្មោះ គី សឺន ភាគទី៥វៀតណាមៗ នៅខែមេសា ឆ្នាំ១៩៧៦ យ៉ា បានឡើងទៅតំបន់១០៥ ប្រជុំគណៈតំបន់និងគណៈស្រុកដោយនាំលេខា និងអនុលេខាតំបន់មាន បងឡាំង ទទួលខាងយោធា, បង សូរុន គឺជាលេខាស្រុក រ៣, បងខាំភូន ខាងសេដ្ឋកិច្ច, ខ្ញុំសង្គមកិច្ចសុខាភិបាល, មិត្តសូភា យោធា, មិត្ត ចាំ វប្បធម៌ (គឺជាលេខាស្រុក រ២)ៗ ចំណែកគណៈស្រុកមាន មិត្ត ស្វាយ លេខាស្រុករ១, មិត្តរ៉ា អនុលេខា, បងឡោក អនុលេខាស្រុក រ២, បងដាក់ អនុលេខាស្រុករ៣, បងគី លេខាស្រុក រ៤, មិត្តខឿន អនុលេខាស្រុករ៤, កាស៊ី លេខាស្រុក រ៥ និង ចាន់ដើរ អនុលេខាៗ

នៅខែមករា ឆ្នាំ១៩៧៧ គណៈតំបន់បានសម្រេចធ្វើសន្និបាតសម្រេចដកការងារពី គណៈ ទាក់ទងបរទេស, ដកភូមិស្រែសង្គមឲ្យទៅស្រុក រ៤ៗ សកម្មភាពក្នុងពេលនោះគឺមិនអនុវត្តភារកិច្ចដែលបក្សប្រគល់ឲ្យ មិនគោរពតាមការចាត់តាំងរបស់គណៈតំបន់មិនចុះដឹកនាំក្នុងក្រសួងរបស់ខ្លួនហើយពេលសន្និបាតមានទំនាស់ជាមួយលេខាតំបន់ៗ កាស៊ី និង ចាន់ ត្រូវសន្និបាតតំបន់ដេញចេញពីគណៈស្រុកកែវស៊ីមា ឲ្យរស់នៅក្នុងមន្ទីរសេដ្ឋកិច្ចតំបន់ ក-១៦ៗ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ យើងឃោសនាបំផុសទំនាស់នៅក្នុងសហគមន៍ ចលនាប្រជាជនឲ្យទាមទារពីសមូហភាពដោះស្រាយការរស់នៅប្រចាំថ្ងៃដូចជាការស៊ីចុក ស្លៀកពាក់ប្រចាំថ្ងៃ និងថ្នាំសង្កូវៗ បន្ទាប់ពីនេះខ្ញុំបានកែប្រែខ្លឹមសារឃោសនាខ្លះឲ្យស្របតាមសភាពការណ៍ថ្មី និងខំប្រឹងធ្វើសកម្មភាពក្បត់បន្ត រហូតដល់ថ្ងៃទី២៨ខែមីនា ខ្ញុំត្រូវបក្សចាប់ខ្លួនតែម្តងៗ

***កំណត់ចំណាំ ៖ អត្ថបទនេះ ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J០០៨៧៨ៗ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ សូ គឹម អាន ហៅ អាចារ្យមុី ពិតប៉ុណ្ណាណានោះទេ?***

# គុយ យ៉ុន គណៈយោធាស្រុកត្របែក

ជាវ៉ារដ្ឋ មេត្តា



យុទ្ធនារីនៅក្នុងសហករណ៍កំពុងជ្រើសរើសគ្រាប់ស្រូវទុកសម្រាប់ធ្វើពូជ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំមានឈ្មោះដើម គុយ យ៉ុន និងឈ្មោះក្នុងជួរបដិវត្តន៍ គុយ សាវ៉ាន ភេទប្រុស អាយុ៣៦ឆ្នាំ (នៅឆ្នាំ១៩៧៦)។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រៃស្មាំង ឃុំពញាលៀង ស្រុកព្រះស្ដេច ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ គុយ យ៉ាន ស្លាប់នៅក្នុងឆ្នាំ១៩៦៨ និងម្ដាយខ្ញុំឈ្មោះ ព្រំ ប៊ុ។ ខ្ញុំមានប្អូនបង្កើតទាំងអស់ចំនួន៨នាក់ និងបានចូលបម្រើបដិវត្តន៍ចំនួន៧នាក់។ បងទី១) គុយ យុន ក្រោយមកធ្វើជាលេខាឃុំរាធរ ស្រុកកោះជ័យ, ទី២) ខ្ញុំ (គុយ យ៉ុន) ទី៣) គុយ ឈុន គឺជាបុគ្គលិកវប្បធម៌, ទី៤) គុយ នៅ គឺជាពេទ្យឃុំពញាលៀង១, ៥) គុយ នាត នៅអង្គភាពឃុំរាធរ, ៦) គុយ ណា អង្គភាពវប្បធម៌, ៧) គុយ ហ៊ាន ពេទ្យតំបន់២៤ និង ទី៨) ប្អូនពៅរស់នៅជាមួយម្ដាយ។

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៥ អង្គការបានរៀបចំឲ្យខ្ញុំមានប្រពន្ធឈ្មោះ ឡុង ខឿន អាយុ២៣ឆ្នាំ គឺប្រជាជននៅស្រុកកោះជ័យ ខេត្តព្រៃវែង។ ប្រពន្ធរបស់ខ្ញុំធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ច ស្រុកត្របែកផ្នែកកាត់ដេរ។

នៅពេលដែលខ្ញុំមានអាយុ៥ឆ្នាំ ឪពុកម្ដាយខ្ញុំបានមករស់នៅក្នុងភូមិស្នាយព្រីមដែលជាស្រុកកំណើតខាងម្ដាយ។ មូលហេតុដែលគ្រួសារខ្ញុំមករស់នៅភូមិស្នាយព្រីមវិញដោយសារមានវៀតណាមបះបោរកាប់សម្លាប់ ឆក់ប្លន់ប្រជាជននៅក្នុងភូមិ។ នៅពេលខ្ញុំអាយុ១១ឆ្នាំ គ្រួសារខ្ញុំត្រឡប់មករស់នៅក្នុងភូមិស្មាំងវិញ។ ពេលខ្ញុំមានអាយុ១៦ឆ្នាំ ឪពុកម្ដាយខ្ញុំនាំខ្ញុំមកនៅវត្តថ្មីស្ថិតនៅឃុំពញាលៀង១។ ក្រោយមកខ្ញុំបួសជានេនបានរយៈពេល១ឆ្នាំ និងបួសជាភិក្ខុបានរយៈពេល២ឆ្នាំ។ នៅឆ្នាំ១៩៦៧ ខ្ញុំទៅប្រឡងយកសញ្ញាបត្រសាលាបាលីរង នៅក្នុងក្រុងព្រៃវែង ហើយខ្ញុំប្រឡងជាប់និងទទួលបានសញ្ញាបត្រ។ បន្ទាប់ពីប្រឡងរួចខ្ញុំបានមកស្នាក់នៅក្នុងវត្តថ្មីបានរយៈពេល១ខែ ទើបខ្ញុំមករស់នៅវត្តទួលសាំង ស្ថិតនៅក្នុងឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង។

នៅក្នុងឆ្នាំ១៩៦៨ ខ្ញុំបានសឹកនិងមករស់នៅផ្ទះបានរយៈពេល២ខែ។ ដោយជីវភាពគ្រួសារមានការខ្វះខាតខ្ញុំបានមករស់នៅជាមួយប្រជាជនដែលមានផ្ទះនៅក្បែរវត្តទួលសាំង។ គាត់ធ្លាប់រស់នៅជាមួយខ្ញុំកាលខ្ញុំបួសជាសង្ឃ។ ខ្ញុំបានរស់នៅជាមួយគាត់និងធ្វើស្រែចម្ការ ដាំសណ្តែក ល្ង ពោត ដោយមានការជួយពីអ្នកភូមិជិតខាង ដូចជា ផ្តល់ដីស្រែឲ្យធ្វើ ផ្តល់កម្លាំងសត្វគោ និងក្របីឲ្យភ្ជួររាស់។ ក្រោយមកឪពុកមារខ្ញុំឈ្មោះ គុយ សាន់បានទិញមង់ខ្នាតតូចឲ្យខ្ញុំទុកនេសាទត្រី។ ក្នុងរយៈពេលដែលខ្ញុំប្រកបមុខរបរនេសាទត្រី ខ្ញុំទទួលបានការអប់រំជាបណ្តើរៗពីបងធុច គឺជាលេខាតំបន់២៣ និង បងភន បច្ចុប្បន្នគឺនៅអង្គភាពកសិកម្មតំបន់២៤ ដោយសារបងទាំងពីរនេះរស់នៅភូមិព្រៃស្វាំងជាមួយខ្ញុំ។

នៅខែកុម្ភៈ ឆ្នាំ១៩៦៩ ខ្ញុំចូលបដិវត្តន៍នៅភូមិព្រៃស្វាំង ដោយមានបងភន ជាអ្នកនាំចូល និង បងធុច គឺជាអ្នកទទួលស្គាល់។ ក្រោយពីខ្ញុំចូលបដិវត្តន៍ ខ្ញុំក៏ចូលនៅក្នុងចលនាយុវជនយុវនារី៣ភូមិ គឺភូមិក្រសាំងទង ភូមិព្រៃស្វាំង និងភូមិទឹកជូរ។ ខ្ញុំមានតួនាទីជាអនុប្រធានសាខាយុវជនឃុំពញាលៀង និងជាទីស្តីការភូមិព្រៃស្វាំង។ នៅខែកុម្ភៈ ឆ្នាំ១៩៧០ ខ្ញុំចូលអង្គការដោយក្លាយជាសមាជិកយុវកកដោយមានសមិត្ត ខាំ សុខ គឺជាអ្នកឧទ្ទេនាម និងសមមិត្តម៉ុង គឺជាអ្នកទទួលស្គាល់។ ខ្ញុំចូលជាសមាជិកអង្គការបន្តទៀតគឺចូលបក្សនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧០ នៅអង្គភាពស្រុកត្របែក ដោយមានសមមិត្តសុខសានអ្នកឧទ្ទេសនាមទី១, សមមិត្តចាន់ថនអ្នកឧទ្ទេសនាមទី២ និងសមមិត្តជ័យ សារិន គឺជាអ្នកទទួលស្គាល់។

រិន គឺជាលេខាស្រុកកំពង់ត្របែក អប់រំខ្ញុំចាប់តាំងពីឆ្នាំ១៩៧៣ និង១៩៧៤ ដោយមានវិធីពីរយ៉ាងគឺអប់រំស្របច្បាប់ គឺឲ្យខិតខំពង្រឹងកម្លាំងបក្សដើម្បីពង្រីកការអប់រំដឹកនាំក្នុងអង្គភាព ប៉ុន្តែខ្លឹមសារមិនមែនផ្អែកលើមាគ៌ាវណ្ណៈរបស់បក្សដោយជ្រើសរើសយកសភាពមិនល្អ ដូចជា សមាសភាពសេរី ភ្លើតភ្លើនពាក់ព័ន្ធនិន្នាការនយោបាយខ្លាំង និងពាលាអាវ៉ាសែ។ មួយផ្នែកទៀតគឺអប់រំចំហរ ដោយលើកឡើងថា នៅប្រទេសវៀតណាមគេមិនខ្វះអ្វីទេ ហើយសម្បូរសប្បាយមានតាំងពីបៀរ អាប៉ោង រហូតដល់វៀតណាមរំដោះ ហើយនៅតែមានល្បែងស៊ីសងស្រីស្រាពេញប្រទេស របបនាយទុន និងឯកជនក៏មានដែរ។ ឯប្រទេសកម្ពុជាយើងខ្វះខាតច្រើនណាស់។ រិន អប់រំនិងមានវិធានការឲ្យខ្ញុំទៅទប់ទឹកទុករហូតធ្វើឲ្យលិចសន្ទូងរលួយសំណាប ដំណាំដាំដុះ លិចផ្ទះសម្បែងរបស់ប្រជាជនមូលដ្ឋាននៅក្នុងឆ្នាំ១៩៧៥។ រិនឲ្យខ្ញុំទៅបើកទឹកបង្ហូរចេញពីប្រឡាយធំឲ្យអស់ពីស្រែហើយគាត់នឹងបញ្ចូលទឹកថ្លាចូលវិញ ប៉ុន្តែមិនឃើញបញ្ចូលទេ ធ្វើឲ្យសន្ទូងខូចអស់។ រិនចាត់តាំងឲ្យខ្ញុំធ្វើការពិនិត្យតាមដានផ្ទៃក្នុងគណៈស្រុក ហើយរាយការណ៍ឲ្យគាត់វិញ ព្រោះគាត់ខ្លាចក្នុងគណៈស្រុកមានគោលបំណងអ្វីផ្សេងមិនល្អចំពោះគាត់។ រិន មានផែនការឲ្យខ្ញុំដាក់ឈ្លបតាមព្រំដែនរាយចម្រូងបន្តិចបន្តួចត្រង់កន្លែងណាដែលសំខាន់ប៉ុណ្ណោះ ហើយឲ្យខ្ញុំយកមីនចេញពីខ្សែបន្ទាត់ព្រំដែន។ ប្រសិនបើឃើញវៀតណាមចូលមកក្នុងទឹកដីខ្មែរឲ្យខ្ញុំបាញ់យ៉ាងណាធ្វើឲ្យខុសនយោបាយបដិវត្តន៍។ រិន ប្រាប់ខ្ញុំឲ្យបន្ថយរបបអាហារនៅក្នុងអង្គភាពដើម្បីសន្សំសំចៃត្រៀមទុកពេលខ្វះខាតទៅថ្ងៃមុខ។ ប៉ុន្តែគោលបំណងយុទ្ធសាស្ត្រគឺដើម្បីឲ្យយុទ្ធជនហូបមិនគ្រប់គ្រាន់និងតឹងតែងលើបញ្ហាហូបចុក។ កន្លងមក លើការស្លៀកពាក់ក៏មានការកាត់បន្ថយដែរ គឺខ្ញុំមិនដែលបើកសម្លៀកបំពាក់បានគ្រប់ម្តងណាទេ រហូតដល់មានការលើកឡើងថា «ធ្វើបដិវត្តន៍ស្លៀកពាក់ដូចឈ្លើយសឹក» ហើយអនុញ្ញាតឲ្យមានគ្រួសារបង្កឲ្យមានភាពគគ្រឹកគគ្រេង រហូតដល់មានសភាពខុសសីលធម៌ទី៦ កើតមានឡើងនៅក្នុងអង្គភាព។ ក្រោយមក ខ្ញុំបានយកទៅអនុវត្តជាក់ស្តែង ដោយបានយកទៅផ្សព្វផ្សាយដល់យុទ្ធជន និងកម្មាភិបាលថ្នាក់ក្រោមៗ។ នៅពេលដែលខាងក្រោមអនុវត្តមិនបាន ខ្ញុំបញ្ចេញអាកប្បកិរិយា អាជ្ញា សម្លុត គម្រាមកំហែង។ ចលនាក្បត់នេះមានឈ្មោះថា ចលនាសេរីនិយមដែលយកសមាសភាពជាប់និន្នាការសង្គមចាស់

*ជាមេភូមិ មេកង ប៉ូលីស ទាហាន សមាសភាព ពាលាអាវ៉ាសែ សន្តិសុខ ធ្វើជាខ្នងបង្អែក។ ចលនាសេរីនិយមនេះបានកើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៥ នៅពេលដែលរិនបានអប់រំខ្ញុំហើយដើមកំណើតដំបូងខ្ញុំមិនបានដឹងពិតប្រាកដទេ។ ម៉្យាងទៀតចលនានេះមានការគាំទ្រពីប្រទេសសូវៀត និងប្រទេសវៀតណាមទាំងផ្លូវចិត្ត និងសម្ភារ តាមរយៈគណៈទាក់ទងវៀតណាមឈ្មោះ បៃម៉ាន់។ ជំនួយដែលវៀតណាមបានផ្តល់ឲ្យមកខ្ញុំមានដូចជា អាអ៊ែ១៥ ចំនួន៧៥ដើម, សេកាសេ ចំនួន៤០ដើម, អឹម៣០ ចំនួន៤ដើម, កាំភ្លើងត្បាល់៦០មីលីម៉ែត្រ ចំនួន៣ដើម, បេ៤០ ចំនួន២ដើម, អឹម៧៩ ចំនួន៦ដើម, កា៥៤ និងអាបេ ចំនួន១២ដើម, ថ្នាំពេទ្យពាធុង ដោយមានបណ្តោយកន្លះម៉ែត្រ ទទឹកពាទឹកនិង កម្ពស់៤តឹក។ សម្ភារទាំងអស់នេះគឺយោធាស្រុកកំពង់ត្របែកជាអ្នកទទួលពី ប៉ៃម៉ាន់ នៅផ្សារពាមបន្ទារ នៅខែតុលា ឆ្នាំ១៩៧៥ ហើយអាវុធនិងសម្ភារទាំងអស់នេះយើងមិនទាន់បានយកមកប្រើប្រាស់ទេ។ ផែនការក្បត់នេះមានទិសដៅវាយរំលំរដ្ឋអំណាច ដណ្តើមអំណាចមកគ្រប់គ្រង និងចាត់ចែងតាមសេរីនិយម។ ក្រោយមកខ្ញុំត្រូវអង្គការចាប់ខ្លួន និងយកមកសួរចម្លើយនៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៦។*

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីសេចក្តីកត់ហេតុសួរចម្លើយឯកសារ J០០២៥៥។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ គុយយ៉ុន ពិតប៉ុណ្ណាណានោះទេ?***



*យោធាខ្មែរក្រហមនៅសមរភូមិ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# សោម ពៅ៖ លេខាសង្កាត់បន្ទាយចក្រី ស្រុកកោះថ្ម័យ តំបន់២៤

ជាវ៉ារដ្ឋ មេត្តា



យុទ្ធនារីខ្មែរក្រហមកំពុងវាយប្រយុទ្ធនៅលើសមរភូមិ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សោម ពៅ និងមានឈ្មោះ បដិវត្តន៍ សោម វិន ជនជាតិខ្មែរ ភេទប្រុស អាយុ៣៨ឆ្នាំ។ ខ្ញុំមានទីលំនៅភូមិភ័គក្រលិស (បច្ចុប្បន្នអាចជាភូមិភក្កនេស្ស) ឃុំត្រកោល (តាកោ) ស្រុកព្រៃវែង (ពោធិរៀង) ខេត្តព្រៃវែង។ ប្រពន្ធរបស់ខ្ញុំឈ្មោះ សំ សឿន ចំណែកឈ្មោះបដិវត្តន៍ ប្អូន សារី រស់នៅភូមិរង្វះមួយរយ បច្ចុប្បន្នភូមិអង្វះមួយរយ ឃុំអន្សោង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ប្រពន្ធខ្ញុំធ្វើការនៅក្នុងមន្ទីរកាត់ដេរស្រុក។

ខ្ញុំបួសជាព្រះសង្ឃអស់រយៈពេល៨ឆ្នាំ នៅវត្តស្វាយសុខា ស្ថិតនៅភូមិស្វាយសុខា ឃុំព្រែកខ្លោង ស្រុកព្រៃវែង ខេត្តព្រៃវែង។ បងខ្ញុំឈ្មោះ ម៉ុក គឺជាអ្នកបំបួសខ្ញុំព្រោះគាត់គឺជាសង្ក្រាជ វត្តស្វាយសុខា។ ចាប់ពីឆ្នាំ១៩៦១ដល់ឆ្នាំ១៩៦២ ខ្ញុំរៀននៅវត្តស្ទឹងស្លូត ស្ថិតនៅឃុំអ្នកលឿង ស្រុកពាមជរ ខេត្តព្រៃវែង។ ខ្ញុំរៀនភាសាបាលី ជាមួយគ្រូ សុខ សិន(បច្ចុប្បន្ននៅចម្ការកៅស៊ូរដ្ឋ) ចំណែកគ្រូ ព្រំ សម្បត្តិ បង្រៀនចំណោទ និងសរសេរតាមសូត្រ។ នៅពេលនោះ គ្រូ ហាយ អេល ក៏បង្រៀនភាសាបាលីដែរ និងជាសង្ក្រាជវត្ត។ ហាយ អេល មានស្រុកកំណើតនៅភូមិពន្លៃ ឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង។ កាលខ្ញុំនៅរៀនទីនោះមានសិស្សចំនួន២០អង្គ។

មិត្តភក្តិដែលខ្ញុំជិតស្និទ្ធជាមួយមានឈ្មោះ សុខ សិន, កៅ មួន, ព្រំ សម្បត្តិ ហៅ មាន និងមានឈ្មោះ

ក្រៅមួយទៀតគឺ ចក្រី, ស្លុត, រដ្ឋ, មុំ មាន, ម៉េង និង ណន នៅស្រុកពាមជរ, ក្រុច, មិ យន (ស្រុកកោះជ័យ), ហាក់ (យោធាភូមិភាគ), ឈួន ប្រធានរងយោធាតំបន់២៤, កង, ស៊ុត គឺជាបញ្ជាការរងតំបន់២៤, ប៉ុល, ផុស, សារ៉ន, វ៉ាន់, វ៉ុន គឺជាលេខាយយោធាតំបន់២៤។ នៅចុងឆ្នាំ១៩៧៤ ខ្ញុំទទួលបានការអប់រំពីសមមិត្ត ឈូក និងសមមិត្ត ចក្រី ។ ខ្លឹមសារដែលសមមិត្ត ឈូក និយាយអប់រំខ្ញុំគឺ «ឥឡូវនេះយើងចប់សង្គ្រាម ប៉ុន្តែការងារពលកម្មកាន់តែខ្លាំងឡើង ប៉ុណ្ណឹងហើយនៅជីវភាពមិនគ្រប់គ្រាន់ទៀត សុខភាពប្រជាជនកាន់តែចោទ ហេវហត់ឈឺ ហើយលទ្ធភាពដោះស្រាយមិនចេញ។ បើប្រៀបធៀបជាមួយប្រទេសដទៃទៀត គឺយើងចាញ់គេ និងមិនជឿនលឿនទេ។ យើងត្រូវយកចិត្តទុកដាក់ប្រមូលកៀងគរកម្លាំងឲ្យប្រជាជនឧបត្ថម្ភយើង ដោយបំបែកកម្លាំងប្រជាជនពីបដិវត្ត» ។ ចំណែកខ្លឹមសារដែលសមមិត្ត ចក្រី អប់រំខ្ញុំគឺ «លើកអំពីបញ្ហាប្រៀបធៀបសម័យមុនសង្គ្រាមមានលក្ខណៈខុសគ្នា យើងខ្វះខាតសម្ភារ ស្បៀងអាហារមិនគ្រប់គ្រាន់ ពីសង្គមចាស់មានហូបគ្រប់គ្រាន់។ ចក្រី បានអប់រំខ្ញុំថា «ខំធ្វើសកម្មភាពទៅចាំចប់ចុងចប់ដើមចាំគិតគ្នា»។ ខ្លឹមសារទាំងអស់នេះខ្ញុំបានយកទៅធ្វើការឃោសនាបំផុសបំផុលប្រជាជន ហើយប្រជាជនមួយចំនួនយល់ស្របតាមការឃោសនានេះ។ ខ្ញុំចាត់តាំងកម្លាំងបន្តទៀតមានឈ្មោះ សុខ នី គឺជាសមាជិកទីពីរក្នុងគណៈស្រុកត្របែក, ទេព កេត គឺជាគណៈកសិកម្មស្រុកត្របែក, ចិន ចន គឺជាប្រធានឃុំក្រសោមអក (កន្សោមអក), ហួត សេង គឺជាប្រធានឃុំពាមទារ (ពាមមន្ទារ), ទឹម អ៊ី គឺជាយុជននៅភូមិប៉ុកទាក ឃុំប្រធាតុ, ម៉េត គឺជាយុវជននៅភូមិជ្រួល ឃុំក្រសោមអក (កន្សោមអក) និងឈ្មោះ កៅ មួន។

នៅក្នុងឆ្នាំ១៩៦៦ ខ្ញុំរៀននៅវត្តកំសាន ស្ថិតនៅខាងត្បូងច្បារអំពៅជាប់នឹងទន្លេបាសាក់ដែលមានចម្ងាយ ២០០ទៅ ៣០០ម៉ែត្រពីមាត់ទន្លេត្រើយខាងកើត និងមានគ្រូបង្រៀនឈ្មោះ បូ ។ បន្ទាប់មកខ្ញុំមកនៅភូមិស៊ីងស្លូត ក្នុងឃុំអ្នកលឿង ស្រុកពាមជរ ខេត្តព្រៃវែង វិញ ដោយសារអាចារ្យ ហាយ អេល ឲ្យខ្ញុំជួយបង្រៀនចំណោទ និងសរសេរតាមសូត្រ ដល់សិស្សថ្នាក់ទី១ ចំនួន២០នាក់។



យោធាខ្មែរក្រហមកំពុងវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម នៅសមរភូមិក្នុងស្រុកប្រសូត្រ ខេត្តស្វាយរៀង។ ខែមករា ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំបានចូលបដិវត្តន៍នៅឆ្នាំ១៩៦៧ នៅវត្តស៊ីងស្លូត ភូមិស៊ីងស្លូត ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែងដែលអ្នកនាំចូលឈ្មោះ កៅ មុន។ មូលហេតុ កៅ មុន អាចអូសទាញខ្ញុំឲ្យចូលបដិវត្តន៍បាន គឺដោយសារគាត់ពន្យល់ខ្ញុំអំពីការជិះជាន់សក្តិភូមិ និងការរំដោះខ្លួន។

នៅក្នុងឆ្នាំ១៩៦៨ ខ្ញុំចេញពីវត្តស៊ីងស្លូតមកវត្តកំរ៉ែង ស្ថិតនៅភូមិកំរ៉ែង ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង បន្ទាប់មកខ្ញុំសឹកតែម្តង។ តាំងពីខ្ញុំចូលបដិវត្តន៍

មកនៅខែឧសភា ឆ្នាំ១៩៦៩ ខ្ញុំទទួលតំណែងជាលេខាសង្កាត់ នៅបន្ទាយចក្រី នៅស្រុកកោះជ័យ។ ចាប់តាំងពីខែឧសភា ដល់ខែតុលា ឆ្នាំ១៩៦៩ អង្គការឲ្យខ្ញុំទទួលការងារនៅសង្កាត់បឹងដោល។ នៅចន្លោះពីខែតុលា១៩៦៩ ដល់ខែកុម្ភៈ ឆ្នាំ១៩៧០ អង្គការចាត់តាំងខ្ញុំឲ្យទៅរៀននៅសាលាភូមិភាគ។ អភិបាលសាលាភូមិភាគឈ្មោះ សោ យ៉ាន់ និង តាម៉ាប់។ នៅពេលខ្ញុំត្រឡប់មកពីរៀនវិញអង្គការឲ្យខ្ញុំទៅទទួលការងារនៅស្រុកត្របែក ដោយមានតួនាទីជាប្រធានស្រុកត្របែក។ ខ្ញុំចូលបក្សនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧០ ដោយមានអ្នកខ្ទេសនាមគឺ បង ឈូក និង បងជ័យ គឺជាអ្នកទទួលស្គាល់។ ក្រោយមកខ្ញុំបានចាត់តាំង ឈ្មោះ ប៉ុក ស៊ាង នៅសហករណ៍ភូមិពោធិ៍ សង្កាត់ប្រធាតុ, យាវ យុន សង្កាត់អន្លោង, ទុំ ប៊ិច នៅអង្គភាពសន្តិសុខស្រុក, សោ សូវេត នៅមន្ទីរពេទ្យមធ្យម ឲ្យធ្វើសកម្មភាពបំបែកកម្លាំងប្រជាជននិងបដិវត្តន៍, ពង្រីកខាងសីលធម៌ទី៦ (កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ) ហើយបង្កើតចោរកម្មឲ្យដើរលួចដើម្បីវាយបដិវត្តន៍។ នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំទទួលឋានៈជាកម្មាភិបាលខេត្តព្រៃវែង។

អង្គការបានចាប់ខ្លួនខ្ញុំមកទីនេះ ព្រោះខ្ញុំបានទទួលការអប់រំ និងចាត់តាំងក្បត់ពីសមមិត្ត ឈូក និង សមមិត្តចក្រី។ ខ្ញុំត្រូវយកមកសួរចម្លើយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៧៦។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីសេចក្តីកត់ហេតុសួរចម្លើយឯកសារ D១២៧៥។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ សោម ពៅ ហៅ សោម វិន ពិតប្រាកដយ៉ាងណានោះទេ?**



យុទ្ធនារីបដិវត្តន៍ខ្មែរក្រហមនៅភូមិភាគបូព៌ារួមជាមួយកងចល័តកំពុងដឹកជញ្ជូនផលស្រូវពីសមរភូមិមុខយកមកទុកនៅសមរភូមិក្រោយ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ម រិន៖ ខ្មែរក្រហមធ្វើឱ្យស្ថានភាពគ្រួសាររបស់ខ្ញុំផ្លាស់ប្តូរទាំងស្រុង

*ភា រស្មី*



*ម៉ម រិន អាយុ៧៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រៃកន្សា ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ម៉ម រិន ភេទស្រី អាយុ៧៩ឆ្នាំ។ សព្វថ្ងៃខ្ញុំរស់នៅភូមិព្រៃកន្សា ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ នៅសម័យសង្គមរាស្ត្រនិយម ជីវភាពក្នុងគ្រួសាររបស់ខ្ញុំមានការលំបាកខ្លាំង ដែលជាហេតុធ្វើឲ្យខ្ញុំមិនបានចូលសិក្សារៀនសូត្រដូចគេ។ នៅឆ្នាំ១៩៦៩ ខ្ញុំរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ ញៀន គុប ពាក់ស័ក្តិមួយ មានតួនាទីបើកប្រាក់ខែឲ្យកូនទាហាន។ កាលនោះខ្ញុំទៅរស់នៅក្នុងទីរួមខេត្តស្វាយរៀង។ បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ បានរយៈពេលពីរខែ ស្ថានភាពនៅក្នុងទីរួមខេត្តស្វាយរៀងមានភាពចលាចល។ ប្តីរបស់ខ្ញុំឲ្យខ្ញុំមករស់នៅជាមួយឪពុកម្តាយនៅក្នុងស្រុកកំពង់ត្របែកមួយរយៈ ព្រោះនៅបន្ទាយកំពង់ចក ស្ថិតនៅខាងជើងទីរួមខេត្តស្វាយរៀង កងទ័ពវៀតណាមខាងជើងធ្វើការវាយប្រហារយ៉ាងខ្លាំង។ នៅឆ្នាំ១៩៧២ កងទ័ពវៀតណាមខាង

ជើង វាយយកបានបន្ទាយកំពង់ចកទាំងមូល ហើយទាហានលន់ នល់ ទាំងអស់រួមជាមួយប្ដីរបស់ខ្ញុំបានផ្លាស់ប្ដូរបន្ទាយមកនៅវត្តព្រៃឆ្លាក់ ក្នុងក្រុងស្វាយរៀងវិញ។ ចំណែកខ្ញុំដែលរស់នៅស្រុកកំពង់ត្របែកគ្រប់គ្រងដោយខ្មែរក្រហម បានតាមមករកប្ដីនៅបន្ទាយកំពង់ចក ក្រែងលោឃើញសាកសពប្ដីរបស់ខ្ញុំ ព្រោះនៅទីនោះមានទាហានលន់ នល់ ស្លាប់ច្រើនណាស់ ប៉ុន្តែខ្ញុំរកមិនឃើញ។ ក្រោយមក ខ្ញុំបានស្នើសុំសំបុត្រធ្វើដំណើរពីខ្មែរក្រហមដើម្បីចូលមកខាងលន់ នល់ ដោយយកលេសថា មកយកប្ដីឲ្យទៅចុះចូល។ ខ្ញុំធ្វើដំណើរមកដល់វត្តព្រៃឆ្លាក់ ក៏ហែកសំបុត្រចោល បន្ទាប់មកបានចូលទៅក្នុងបន្ទាយដើម្បីតាមរកប្ដីរបស់ខ្ញុំ។ ពេលនោះមានកូនទាហានម្នាក់បានរត់ទៅប្រាប់ប្ដីរបស់ខ្ញុំថា លោកស្រីទើបតែធ្វើដំណើរមកដល់។ នៅក្នុងបន្ទាយ ខ្ញុំឃើញមានឡាន ១២គ្រឿងត្រៀមចេញដំណើរទៅវាយបន្ទាយខ្មែរក្រហមដើម្បីរំដោះខ្ញុំ និងប្រពន្ធទាហានផ្សេងទៀត ប៉ុន្តែពេលខ្ញុំទៅដល់ក៏អាក់ខានវិញ។

នៅឆ្នាំ១៩៧៣ ប្ដីរបស់ខ្ញុំត្រូវបានថ្នាក់លើបញ្ជូនឲ្យទៅមើលការខុសត្រូវនៅខេត្តកំពង់ចាម ហើយខ្ញុំទៅជាមួយដែរ។ ពេលទៅដល់កំពង់ចាមមិនបានប៉ុន្មាន ប្ដីរបស់ខ្ញុំបានឲ្យខ្ញុំជិះយន្តហោះមករស់នៅទីក្រុងភ្នំពេញ ព្រោះប្ដីរបស់ខ្ញុំជាប់វាយជាមួយទាហានវៀតណាមខាងជើង។ ក្រោយមក ខ្ញុំស្នើអ៊ំរបស់ខ្ញុំឈ្មោះ កង សោម ដែលធ្វើការនៅបន្ទាយទាហាននៅពោធិ៍ចិនតុង សុំឧទ្ធម្ភាគចក្រស្លាបកាត់ឲ្យជូនខ្ញុំទៅជួបប្ដីនៅកំពង់ចាម។ ខ្ញុំធ្វើដំណើរតាមឧទ្ធម្ភាគចក្រមកចុះនៅភ្នំប្រុស-ភ្នំស្រី។ ពេលមកដល់ មានកូនទាហានម្នាក់យករ៉ឺម៉កមកដឹកខ្ញុំទៅបន្ទាយស៊ុបនៅជើងព្រៃ គឺជាកន្លែងដែលប្ដីរបស់ខ្ញុំប្រចាំការ។ ពេលទៅដល់ភ្លាម ប្ដីរបស់ខ្ញុំបានសួរខ្ញុំអំពីមធ្យោបាយធ្វើដំណើរ ហើយគាត់បានស្ដីបន្ទោសខ្ញុំ ព្រោះឧទ្ធម្ភាគចក្រនោះទាហានទុកធ្វើសង្គ្រាម។ ខ្ញុំរស់ជាមួយគ្រួសារប្អូនថ្លៃស្រីរបស់ខ្ញុំដែលកំពុងមានផ្ទៃពោះ ហើយក្រោយមកកើតបានកូនភ្លោះពីរនាក់។

នៅឆ្នាំ១៩៧៤ ដោយសារតែការប្រយុទ្ធគ្នានៅកំពង់ចាមកាន់តែខ្លាំង គ្រួសារប្អូនថ្លៃរបស់ខ្ញុំត្រូវបានផ្ទេរឲ្យទៅប្រចាំការនៅខេត្តកំពត ចំណែកខ្ញុំត្រូវបានបញ្ជូនឲ្យមករស់នៅក្នុងទីក្រុងភ្នំពេញវិញ។ មុនដំបូងខ្ញុំដណ្ដើមឡើងជិះឧទ្ធម្ភាគចក្រ ប៉ុន្តែត្រូវកូនទាហានចាប់ទាញជើងធ្លាក់មកដី ដូច្នេះខ្ញុំបានប្ដូរមកជិះកប៉ាល់វិញ។ នៅតាមផ្លូវខ្មែរក្រហមបានបាញ់ជាច្រើនគ្រាប់សំដៅមកកប៉ាល់។ ដោយសារតែមានទាហានតិចតួច ដូច្នេះខ្ញុំបានចូលទៅជួយហុចគ្រាប់ផ្លោងឲ្យទាហានលន់ នល់ ដើម្បីបាញ់តតាំងពីកប៉ាល់សំដៅទៅខ្មែរក្រហមវិញ។ ពេលមកដល់ភ្នំពេញខ្ញុំយកមាសទៅលក់យកលុយដើម្បីទិញផ្ទះនៅផ្សារកណ្ដាលស្នាក់នៅ។ ចំណែកប្ដីរបស់ខ្ញុំបានជិះកប៉ាល់មកតាមក្រោយ។



រិន និងប្ដី ថតនៅឆ្នាំ១៩៧០ នៅខេត្តស្វាយរៀង។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

យើងរស់នៅក្នុងទីក្រុងភ្នំពេញរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

យោធាខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ឲ្យចេញពីទីក្រុងភ្នំពេញ ដោយលើកហេតុផលថា សម្អាតទីក្រុង។ ប្ដីរបស់ខ្ញុំបានយករទេះដឹកទឹកកកដើម្បីដឹកអីវ៉ាន់ និងក្មួយក្មេងៗពីរនាក់ចេញពីទីក្រុង ប៉ុន្តែពេលចេញពីផ្ទះបានបន្តិចយើងស្នើសុំខ្មែរក្រហមត្រឡប់មកផ្ទះវិញព្រោះភ្លេចមនុស្សម្នាក់។ គ្រាន់តែគ្រួសាររបស់ខ្ញុំហៀបនឹងបកក្រោយ ស្រាប់តែយោធាខ្មែរក្រហមម្នាក់ទាញកាំភ្លើងបម្រុងបាញ់ប្ដីរបស់ខ្ញុំ។ ឃើញដូច្នេះ ខ្ញុំទាញប្ដីរបស់ចេញ ហើយរត់ទៅចាប់កាណុងកាំភ្លើងរបស់យោធាខ្មែរក្រហមឡើងទៅលើ។ យោធាខ្មែរក្រហមបានបាញ់រះឡើងលើអស់គ្រាប់មួយបង់។ បន្ទាប់មក យោធាខ្មែរក្រហមម្នាក់ទៀតបានរុញខ្ញុំឲ្យដួល រួចស្ដីឲ្យខ្ញុំថា «ឯងក៏ឆ្លាស់ម៉្លេះ»។ ខ្ញុំឆ្លើយតបវិញថា «បើមិនឆ្លាស់ម៉េច បើអ្នកឯងទាញកាំភ្លើងមកបាញ់មនុស្សបែង មិនស្លាប់អស់ហើយ» ហើយគ្រួសាររបស់ខ្ញុំក៏ធ្វើដំណើរបន្តទៅមុខទៀត។ នៅតាមផ្លូវទៅខេត្តកំពង់ចាម ខ្ញុំឃើញយោធាខ្មែរក្រហមបាញ់ប្រជាជនស្លាប់ជាច្រើននាក់ ដោយសារតែប្រជាជនប្រឆាំងមិនចង់ចេញពីផ្ទះ។ សាកសពខ្លះបានជះក្លិនស្អុយ និងខ្លះទៀតទើបតែស្លាប់ថ្មីៗ។ ពេលនោះក្មួយក្មេងៗរបស់ខ្ញុំយំយ៉ាងខ្លាំង ខ្ញុំបានយកក្មួយទៅឲ្យមើលមនុស្សប្រុសដែលអង្គុយក្នុងឡាន ហើយនិយាយបន្លាចក្មួយថា «បើយំប្រយ័ត្នតានៅក្នុងឡានវាយ» ប៉ុន្តែមនុស្សនៅក្នុងឡានមិនឆ្លើយតបទេ។ ពេលខ្ញុំមើលមនុស្សនៅក្នុងកាន់តែជិតទើបដឹងថាគាត់បានស្លាប់ហើយ ដោយកូនចៅរបស់គាត់បានទុក



រិន (៣៨ឆ្នាំ) និងប្អូនស្រី ថតដោយពាក់ឯកសណ្ឋានយោធាក្នុងទសវត្សរ៍ឆ្នាំ១៩៨០។ ឯកសណ្ឋាននោះមិនមែនជារបស់ រិន ទេ ហើយ រិន ក៏មិនធ្វើការក្នុងជួរកងទ័ពដែរ។ ដោយសារតែស្រឡាញ់ និងនឹកប្ដីខ្លាំងពេកទើប រិន ខ្ចីឯកសណ្ឋានយោធាមកពាក់ថតរូប។ (ដេង ពង្សរ៉ាស៊ី /មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡានបោល រួចធ្វើដំណើរទៅបាត់អស់។ គ្រួសាររបស់ខ្ញុំធ្វើដំណើរទៅដល់កំពង់ចាមរួចត្រឡប់មកព្រៃវែងវិញ។ គ្រួសារខ្ញុំធ្វើដំណើរកាត់តាមឃុំទឹកថ្លា ស្រុកស្វាយអន្ទរ ឆ្លងមកស្រុកកំពង់ត្របែក។ នៅតាមផ្លូវ ខ្ញុំបានបបួលប្ដីរបស់ខ្ញុំទៅរស់នៅខេត្តស្វាយរៀង ព្រោះនៅជិតប្រទេសវៀតណាម។ ខ្ញុំគិតថាបើមានហេតុការណ៍កើតឡើង យើងអាចរត់ចូលទឹកដីវៀតណាមបានដោយងាយ ប៉ុន្តែប្ដីរបស់ខ្ញុំបដិសេធព្រោះគាត់ចង់មករស់នៅជាមួយម្ដាយរបស់ខ្ញុំ។ ប្ដីរបស់ខ្ញុំជឿថា បដិវត្តន៍មិនមានសម្លាប់មនុស្សឡើយ។ គ្រួសាររបស់ខ្ញុំធ្វើដំណើររយៈពេល ១ខែ ទើបមកដល់ស្រុកកំណើតរបស់ខ្ញុំ។ ខ្ញុំរស់នៅផ្ទះបានប្រហែលមួយសប្ដាហ៍ អង្គការបានស្នើយកប្ដីរបស់ខ្ញុំទៅរៀនសូត្រ។ បងប្អូននៅក្នុងភូមិបានមកប្រាប់ខ្ញុំថា ប្ដីរបស់ខ្ញុំត្រូវខ្មែរក្រហមយកទៅសម្លាប់ហើយ និងឲ្យខ្ញុំខិតខំធ្វើការក្រែងលោបានរស់ជីវិត។ ខ្មែរក្រហមដឹងថា ប្ដីរបស់ខ្ញុំគឺជាទាហានលន់នល់។ នៅក្នុងភូមិ ខ្មែរក្រហមបានប្រើខ្ញុំឲ្យហាលដីលេខមួយ (លាមកមនុស្ស) និងរែកដី។ រហូតដល់ខែវស្សា ទើបខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅស្ទូងស្រូវ និងច្រូតស្រូវពេលរដូវស្រូវទុំ។

នៅដើមឆ្នាំ១៩៧៦ មានការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងយោធាខ្មែរក្រហមនៅតាមបណ្ដោយព្រំដែន ហើយបានបណ្ដាលឲ្យយោធាខ្មែរក្រហមស្លាប់អស់ជាច្រើន។ នៅពេលនោះ ខ្មែរក្រហមបានចាត់តាំងខ្ញុំជាមួយកងចល័តនារីទៅសែងសាកសពទាហាន និងអ្នករបួសមកព្យាបាលនៅមន្ទីរពេទ្យក្បាលថ្នល់។ អំឡុងឆ្នាំ១៩៧៦ ដដែល ខ្មែរក្រហមចាត់តាំងខ្ញុំទៅធ្វើដីសណ្ដរនៅព្រៃកណ្ដួចជាមួយកងចល័តនារីផ្សេងទៀត ព្រោះខ្ញុំមិនទាន់មានកូន។ នៅព្រៃកណ្ដួចប្រជាជនមូលដ្ឋានរើសអើងខ្ញុំខ្លាំងណាស់ ហើយប្រសិនបើមានការប្រជុំផ្សេងៗ ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនថ្មីចូលរួមប្រជុំទេ។ ខ្ញុំធ្លាប់បានលួចស្ដាប់ខ្មែរក្រហមប្រជុំម្ដង ដើម្បីចង់ដឹងថាខ្មែរក្រហមមានផែនការអ្វីខ្លះ។ ខ្ញុំស្ដាប់ឮកម្មាភិបាលខ្មែរក្រហមនិយាយប្រាប់ប្រជាជនមូលដ្ឋានកុំឲ្យមកស្និទ្ធស្នាលជាមួយប្រជាជនថ្មី។ នៅក្នុងស្រុកកំពង់ត្របែក ប្រជាជនមូលដ្ឋានមានការរើសអើងប្រជាជនថ្មីយ៉ាងខ្លាំង ព្រមទាំងចាត់តាំងប្រជាជនថ្មីឲ្យធ្វើការងារធ្ងន់ធ្ងរដែលជាហេតុធ្វើឲ្យប្រជាជនថ្មីមួយចំនួនលេបគ្រាប់ស្លែងសម្លាប់ខ្លួន។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រឡប់មកធ្វើការនៅក្នុងភូមិវិញ។ ខ្មែរក្រហមបានដាក់វេនឲ្យកងរបស់ខ្ញុំដាំបាយ និងបុកស្រូវ ប៉ុន្តែខ្ញុំមិនសូវបានធ្វើការក្នុងកងទេ ព្រោះអង្គការចាត់តាំងខ្ញុំនិងកងចល័តនារីមួយចំនួនទៅសែងអ្នករបួស និងអ្នកស្លាប់ ពីព្រំដែនវៀតណាមយកមកព្យាបាលនៅមន្ទីរពេទ្យ ស្ថិតនៅភូមិព្រៃម្លូង ឃុំព្រៃពោន ស្រុកកំពង់ត្របែក។ នៅក្នុងឆ្នាំ១៩៧៧ មានទាហានខ្មែរក្រហមជាច្រើននាក់បានស្លាប់ ព្រោះខ្មែរក្រហមបញ្ជូនឲ្យយោធាជិះដើមចេកឆ្លងទឹកទៅវាយវៀតណាម ប៉ុន្តែដោយសារវៀតណាមស៊ើបដឹងមុន ក៏ចាំបាញ់ស្នាក់។ នៅពេលយប់ ប្រធានសហករណ៍ឈ្មោះ ជីម យន បានបញ្ជូនឲ្យកងនារីទាំងអស់នៅច្រូតស្រូវនៅភូមិក្រាំងលាវ ចំណែកពេលថ្ងៃយើងត្រូវច្រូតស្រូវនៅជិតៗភូមិ។ យើងទៅច្រូតស្រូវនៅភូមិក្រាំងលាវពេលយប់ដោយសារពេលថ្ងៃ កងទ័ពវៀតណាមចាំបាញ់ស្នាក់នៅពេលឃើញមានមនុស្សទៅក្បែរព្រំដែន។ ដូច្នេះយើងត្រូវលួចចូលច្រូតស្ងាត់ៗ មិនឲ្យវៀតណាមឃើញឡើយ។ នៅយប់មួយ ពេលដែលខ្ញុំកំពុងតែច្រូតស្រូវ កងទ័ពវៀតណាមបានបាញ់គ្រាប់ផ្លោងចូលមកធ្វើឲ្យកងចល័តនាំគ្នារត់ និងខ្លះទៀតបានស្លាប់ដោយសារត្រូវគ្រាប់។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមចាប់ផ្ដើមជម្លៀសប្រជាជនថ្មីទាំងអស់ឲ្យទៅរស់នៅខេត្តពោធិ៍សាត់។ ដំបូងប្រធានសហករណ៍ ឈ្មោះ យន មិនបញ្ជូនគ្រួសារខ្ញុំទៅខេត្តពោធិ៍សាត់ទេ ប៉ុន្តែដោយសារអ្នកភូមិទិតៀនច្រើនពេក ទើបប្រធានសហករណ៍បញ្ជូនគ្រួសាររបស់ខ្ញុំទៅជាមួយប្រជាជនផ្សេងទៀត។ ខ្ញុំនិងប្អូនថ្លៃរបស់ខ្ញុំ រួមជាមួយក្មួយភ្លោះពីរនាក់ទៀតបានដើរពីកំពង់ត្របែករហូតទៅដល់អ្នកលឿង ដើម្បី

ឡើងជិះកប៉ាល់ទៅក្រុងភ្នំពេញ។ នៅពេលដែលប្រជាជនឡើងលើកប៉ាល់ពេញ អ្នកបើកបរចាប់ផ្តើមចេញដំណើរ។ ប៉ុន្តែពេលទៅដល់កណ្តាលទន្លេស្រាប់តែយោធាខ្មែរក្រហមម្នាក់ពាក់អាវពោងរួចជាស្រេចបានទៅដកឆ្នុកកប៉ាល់ដើម្បីឲ្យទឹកហូរចូល។ ឃើញដូច្នេះ អ៊ំប្រុសម្នាក់ដែលនៅជិតខ្ញុំ បានស្រែកគំរាមថា បើមិនចុកឆ្នុកវិញ គាត់នឹងយកដកវែកវាយ។ ពួ ដូច្នេះយោធានោះព្រមធ្វើតាម ហើយយើងធ្វើដំណើរដោយសុវត្ថិភាពរហូតដល់ទីក្រុងភ្នំពេញ។ ពេលទៅដល់ទីក្រុងភ្នំពេញ ប្រជាជនទាំងអស់ទទួលរបបអាហារ ខោអាវថ្មី និងក្រមាថ្មី និងរង់ចាំជិះរថភ្លើងបន្តទៀត។ ប្រជាជនទាំងអស់ចាប់ផ្តើមឡើងជិះលើរថភ្លើងដើម្បីធ្វើដំណើរទៅដល់ខេត្តពោធិ៍សាត់ បន្ទាប់មកក៏មានឡានមកដឹកទៅដាក់នៅតាមការដ្ឋានរៀងៗខ្លួន។ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅនៅជិតវត្តកណ្តាល ហើយនៅទីនោះខ្ញុំឃើញមានរណ្តៅសាកសពជាច្រើន។ នៅកន្លែងស្នាក់នៅ មានអ៊ំម្នាក់និយាយប្រាប់ខ្ញុំថា ក្រុមរបស់ខ្ញុំសំណាងជាងគេ ព្រោះអង្គការមិនយកទៅសម្លាប់ដូចក្រុមមុនៗ។ ពេលឮដូច្នេះ ខ្ញុំកាន់តែខំប្រឹងធ្វើការបន្ថែមទៀត ព្រោះអ្នកដែលមិនធ្វើការ ឬធ្វើឲ្យខូចរបស់ប្រើប្រាស់ ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលភ្លាមៗ។ ពេលល្ងាច ខ្មែរក្រហមហៅខ្ញុំទៅសួរអំពីប្រវត្តិការងារពីមុនមក ព្រោះឃើញខ្ញុំចេះគ្រប់ការងារទាំងអស់ដែលខ្មែរក្រហមដាក់ឲ្យធ្វើ។ ខ្ញុំបានហូបបាយឆ្អែត ហូបស្ករ ហើយខ្ញុំអាចបេះផ្លែឈើព្រៃហូបបន្ថែមទៀត ព្រោះអង្គការឃើញខ្ញុំធ្វើការងារបានល្អជាងគេ។

នៅដើមឆ្នាំ១៩៧៩ ខ្មែរក្រហមចាត់តាំងឲ្យខ្ញុំទៅដេរខោអាវចាស់ៗ ដែលសល់ពីអ្នកស្លាប់ យកមកចែកឲ្យប្រជាជននៅក្នុងតំបន់ដែលខ្ញុំរស់នៅ។ នៅពេលដែលខ្ញុំចែកខោអាវរួច ស្រាប់តែឃើញកងទ័ពវៀតណាមចូលមកដល់ ដូច្នេះខ្មែរក្រហមចាប់ផ្តើមកៀរប្រជាជនចូលទៅក្នុងព្រៃ។ ចំណែកគ្រួសាររបស់ខ្ញុំបបួលគ្នាត្រឡប់មកស្រុកវិញ។ ពេលនោះ យោធាខ្មែរក្រហមបានជិះសេះតាមពីក្រោយ ប៉ុន្តែពេលឃើញខ្ញុំមានកាំបិតបម្រុងគតដៃក៏ត្រឡប់ទៅវិញបាត់។ នៅតាមផ្លូវយោធាខ្មែរក្រហមបានលួចស្ទាក់បាញ់គ្រួសារខ្ញុំនិងប្រជាជនផ្សេងទៀត។ ខ្ញុំបម្រុងចូលទីក្រុងភ្នំពេញ ប៉ុន្តែកងទ័ពវៀតណាម និងកងទ័ពរណសិរ្ស បានហាមឃាត់មិនឲ្យចូល ដូច្នេះខ្ញុំបន្តដំណើរមកព្រៃវែងតែម្តង។ ខ្ញុំធ្វើដំណើរជាង១០ថ្ងៃបានមកដល់ស្រុកកំពង់ត្របែក។ ខ្ញុំបានជួបម្តាយឪពុក បងប្អូន និងរស់នៅជាមួយគ្នារហូតមកដល់សព្វថ្ងៃ។ ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំបាត់បង់ប្តីជាទីស្រឡាញ់ និងប្អូនប្រុសរបស់ខ្ញុំម្នាក់ ដែលផ្លាស់ទៅប្រចាំការនៅខេត្តកំពតនៅក្នុងសម័យ លន់ នល់។



វាលស្រែក្នុងឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិធីសម្ពោធចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ ពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម

**ទូច វណ្ណាត**



ការចាក់បញ្ចាំងវីដេអូឯកសារ «កុំស្មានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រី"រ៉ក់ អេនរ៉ូល» នៅក្នុងពិធីសម្ពោធចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃព្រហស្បតិ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គាំទ្រដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សំណង់ចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម និងការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅកណ្ដាលវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ កម្មវិធីពិធីសម្ពោធចេតីយ៍មានការចូលរួមពីលោក សៀង ស៊ីផាន ក្រុមប្រឹក្សាឃុំគគរ, លោកស្រី នែនស៊ី អ៊ីសស្ទិក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID), អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ, លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

ជាកិច្ចចាប់ផ្ដើម លោក សៀង ស៊ីផាន ក្រុមប្រឹក្សាឃុំគគរ ថ្លែងអំពីសារសំខាន់នៃការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ លោក ស៊ីផាន រំឭកអំពីរឿងរ៉ាវដែលខ្លួនបានឆ្លងក្នុងរបបខ្មែរក្រហម រួមមាន ការឃ្លាតឆ្ងាយពីក្រុមគ្រួសារ ការអត់ឃ្លាន និងការកាប់សម្លាប់។ លោក ស៊ីផាន បានបញ្ជាក់ថា «រឿងរ៉ាវរបស់ខ្ញុំ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចំការសាមសិប គឺត្រូវបានរំឭកនៅ ទីតាំងចេតីយ៍



ពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកស្រី ណែនស៊ី អ៊ីសស្ទ៊ិក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ថ្លែងសុន្ទរកថា នៅក្នុងពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ថ្ងៃព្រហស្បតិ៍ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២២។

ដែលជាទីតាំងប្រវត្តិសាស្ត្រ»។ លោក ស៊ីផាន បានថ្លែងអំណរគុណដល់ម្ចាស់ជំនួយគឺទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ដែលបានសាងសង់ចេតិយ៍នេះ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានរៀបចំកម្មវិធីពិធីសម្ពោធនេះឡើង។

លោកស្រី ណែនស៊ី អ៊ីសស្ទ៊ិក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ថ្លែងអំពីការពេញចិត្ត និងគាំទ្រចំពោះការផ្តួចផ្តើមគំនិតក្នុងការសាងសង់ចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហមនៅក្នុងមូលដ្ឋាន។

លោក តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិគគរ ថ្លែងថា «ថ្ងៃនេះគឺជាថ្ងៃដ៏មានសារសំខាន់ចំពោះខ្ញុំ និងអ្នកភូមិចំការសាមសិប ក្នុងការដាក់សម្ពោធសំណង់ចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។ ចេតិយ៍នេះគឺជាទីតាំងរំឭកអំពីប្រវត្តិរឿងរ៉ាវអំពីការរស់នៅក្នុងរបបខ្មែរក្រហម និងការចងចាំអំពីរឿងរ៉ាវទុក្ខលំបាករបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិចំការសាមសិប ឃុំគគរ បន្តចូលរួមផ្តួចផ្តើមគំនិត និងចែករំលែករឿងរ៉ាវរបស់ខ្លួនដែលបានឆ្លងកាត់ទៅដល់ក្មេងជំនាន់ក្រោយដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ។ ជាចុងក្រោយ ខ្ញុំបាទតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិចំការសាមសិប សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានឧបត្ថម្ភក្នុងការសាងសង់ចេតិយ៍ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងក្រុមការងារដែលបានគាំទ្រដល់គំនិតផ្តួចផ្តើមនេះឲ្យកើតចេញជារូបរាង។ សូមអរគុណដល់អ្នកស្ម័គ្រចិត្តកម្ពុជា ដែលបានចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយកចិត្តទុកដាក់លើសុខភាពរបស់គាត់»។

បន្ទាប់ពីការថ្លែងសុន្ទរកថា គណៈអធិបតី លោកតាលោកយាយ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សចូលរួមពិធីបង្វិលពពិលនៅជុំវិញចេតិយ៍ចំនួន៣ជុំ បន្ទាប់មកប្រគេនទេយ្យទានដល់ព្រះសង្ឃ និងសូត្រ



ពិធីសម្ពោធចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មន្តបង្សុកូលឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម។

ស្របពេលកម្មវិធីសម្ពោធចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម ក្រុមការងាររមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំកម្មវិធីមួយចំនួនទៀតដូចខាងក្រោម៖

## ពិព័រណ៍រូបថតអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

នៅវេលាម៉ោង៣:៣០នាទីរសៀល អ្នកស្ម័គ្រចិត្តកម្ពុជា ជំនាន់ទី៣ ប្រចាំខេត្តកំពង់ចាម រៀបចំដាក់តាំងពិព័រណ៍រូបថតអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ការចាប់ផ្តើមការសាងសង់សំណង់ចេតីយ៍ និងសកម្មភាពការងាររបស់ស្ម័គ្រចិត្តកម្ពុជាចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅមូលដ្ឋាន។ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សនៃអនុវិទ្យាល័យគគរ និងអ្នកភូមិជាច្រើនបានចូលទស្សនាពិព័រណ៍រូបថតនេះ។ ខាងក្រោម គឺជាទស្សនៈយល់ឃើញរបស់អ្នកចូលរួម៖

អ៊ំប្រុស **អៀង សាររឿន** យល់ថា «ការដាក់តាំងបង្ហាញរឿងរ៉ាវរបស់អ្នកដែលបានឆ្លងកាត់របបខ្មែរក្រហម បានរំឭកដល់ខ្ញុំអំពីការចងចាំមិនអាចបំភ្លេចបាននៃការបាត់បង់សាច់ញាតិ ការលំបាក និងការកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម។ ពិព័រណ៍នេះមានសារសំខាន់ណាស់ដើម្បីឲ្យក្មេងជំនាន់ក្រោយយល់ដឹងអំពីប្រវត្តិសាស្ត្រ»។

លោកយាយ **មុយ ហ៊ាង** លើកឡើងថា «នៅពេលខ្ញុំឃើញរូបភាព និងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀត ខ្ញុំនឹកឃើញដល់ពេលវេលាលំបាកដែលខ្ញុំធ្វើការនៅកងចល័តនារីនៅក្នុងរបបខ្មែរក្រហម»។

លោកគ្រូ **រស់ បញ្ញា** បង្រៀនមុខវិទ្យាប្រវត្តិសាស្ត្រនៅអនុវិទ្យាល័យភូមិថ្មី បង្ហាញចំណាប់អារម្មណ៍ថា ការដាក់តាំងពិព័រណ៍នៅទីតាំងចេតីយ៍នេះ គឺល្អខ្លាំងណាស់ដើម្បីផ្តល់ការយល់ដឹងពីរឿងរ៉ាវ



លោកស្រី នែនសុី អុីសស្ទីក ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ចូលរួមពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងរបបខ្មែរក្រហមបន្ថែមទៀត ដើម្បីរំឭកដល់ប្រជាជនកម្ពុជាដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំស្នើសុំឲ្យមានការដាក់តាំងពិព័រណ៍បែបនេះបន្តទៀត។ ខ្ញុំនឹងដឹកនាំសិស្សមកធ្វើទស្សនកិច្ចនៅទីតាំងចេតិយ៍នេះនាពេលអនាគត។

## ការចាក់បញ្ចាំងខ្សែវីដេអូឯកសារ «កុំស្មានបងភ្លេច៖ ខ្មែរបាត់បង់តន្ត្រី រ៉ក់ អេន រ៉ូល»

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំការចាក់បញ្ចាំងវីដេអូរឯកសារ ចំណងជើងថា **«កុំស្មានបងភ្លេច»** ដែលបង្ហាញអំពីតន្ត្រី វប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា។ ការបញ្ចាំងវីដេអូឯកសារនេះ គឺធ្វើឡើងនៅកណ្តាលវាលស្រែជិតទីតាំងចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម ដោយមានការចូលរួមទស្សនារបស់អ្នកភូមិចំការសាមសិបជាច្រើន។ ការបញ្ចាំងវីដេអូឯកសារនេះ ចាប់ផ្តើមពីវេលាម៉ោង៦:៣០នាទីល្ងាចដល់វេលាម៉ោង៨:៣០នាទីយប់។



មន្ត្រីនគរបាលកំពុងមើលពិព័រណ៍រូបថតនៅក្នុងពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សានុសិស្សចូលរួមពិធីសម្ពោធចេតិយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងាររមជ្ឈមណ្ឌលឯកសារកម្ពុជាដាក់តាំងពិព័រណ៍រូបថតនៅក្នុងពិធីសម្ពោធចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។(អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)





ចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការដាក់តាំងពិព័រណ៍រូបថតនៅក្នុងពិធីសម្ពោធចេតីយ៍រំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីរបបខ្មែរក្រហម នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៣ខេត្តកំពង់ចាម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សៀ ណាន ៖ ពិការជើងដោយសារគ្រាប់មីន

ង៉ាន់ វីន



សៀ ណាន មានអាយុ៨៤ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិត្រពាំងផ្អែល ឃុំម្រោម ស្រុកអង្គរជ័យ ខេត្តកំពត។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សៀ ណាន មានអាយុ៨៤ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិត្រពាំងផ្អែល ឃុំម្រោម ស្រុកអង្គរជ័យ ខេត្តកំពត។ ណាន មានប្តីឈ្មោះ ពៅ ឃិន និងមានកូនប្រុសស្រីចំនួន៦នាក់ ក្នុងនោះមានប្រុសចំនួន៥នាក់ និងស្រីចំនួន១នាក់ ។

កាលពីសម័យ លន់ នល់ ណាន រស់នៅទីក្រុងភ្នំពេញ។ ណាន មានមុខរបរជាអ្នកលក់បន្លែ ចំណែកប្តីរបស់គាត់គឺជា ទាហាន លន់ នល់។ ប្តីរបស់ ណាន មិនមានប្រាក់ខែច្រើនទេ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ណាន និងក្រុមគ្រួសារ ត្រូវយោធាខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅតាមតំបន់ជនបទ។ ណាន បានធ្វើដំណើរមកដល់ស្រុកអង្គរជ័យ។ ដោយសារតែ ណាន ធ្លាប់រស់នៅភ្នំពេញ ទើបអង្គការចាត់ទុក ណាន គឺជាប្រជាជន១៧មេសា។ អង្គការដាក់ឲ្យគ្រួសាររបស់ ណាន រស់នៅដោយឡែក ដោយមិនឲ្យរស់នៅលាយឡំជាមួយអ្នកមូលដ្ឋានឡើយ។ ខ្មែរក្រហមបានយកកូនរបស់ ណាន ទាំង៥នាក់ឲ្យទៅរស់នៅក្នុងកងកុមារដោយមិនឲ្យរស់នៅជាមួយម្តាយ។ អង្គការប្រើ ណាន និងប្រជាជនផ្សេងទៀតឲ្យធ្វើការហួសកម្លាំង និងមិនផ្តល់អាហារឲ្យហូបចុកគ្រប់គ្រាន់ឡើយ។ ណាន រស់នៅឃ្លាតឆ្ងាយពីក្រុមគ្រួសារបងប្អូន និងភ័យខ្លាចខ្លាចជារៀងរាល់ថ្ងៃ។ ក្រោយពីរបបខ្មែរក្រហមដួលរលំ ណាន បានមក នៅក្នុងស្រុកអង្គរជ័យដដែលជាមួយនឹងក្រុមគ្រួសារ។

នៅឆ្នាំ១៩៨៣ ពេល ណាន ទៅកាប់ឈើនៅភ្នំម្រោមដើម្បីយកមកប្រើប្រាស់ ក៏បានជាន់មីនធ្វើឲ្យគាត់ពិការជើងខាងស្តាំ ដែលពេលនោះគាត់ទើបតែសម្រាលកូនបានរយៈពេល៥ខែតែប៉ុណ្ណោះ។ នៅក្នុងឆ្នាំ១៩៩១ មានមនុស្សបានយកគ្រាប់មីនមកដាក់ក្នុងចម្ការបន្លែរបស់គាត់ ហើយពេលដែលប្តីរបស់ ណាន ដើរទៅចម្ការដូចសព្វដង ក៏ជាន់មីនបណ្តាលឲ្យពិការជើងម្ខាងដែរ។ រយៈពេល៥ឆ្នាំក្រោយមក ប្តីរបស់ ណាន បានស្លាប់។ ណាន រស់នៅជាមួយនឹងកូនៗចំនួន៦នាក់ ហើយបន្ទុកគ្រួសារទាំងអស់ត្រូវធ្លាក់មកលើ ណាន។ ណាន ខិតខំដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនៗឲ្យបានរស់រហូតមកដល់សព្វថ្ងៃ។ បច្ចុប្បន្ន ណាន កាន់តែមានវ័យចំណាស់ហើយភ្នែករបស់គាត់ក៏ស្រវាំង។ ណាន ដើរដោយប្រើឈើច្រត់ទប់កុំឲ្យដួល។

ណាន មានអារម្មណ៍ធូរស្រាលដោយសារគាត់បាននិយាយរឿងរ៉ាវដែលគាត់ធ្លាប់បានឆ្លងកាត់ពីរបបខ្មែរក្រហម។ ដោយសារតែមានការលំបាកពេលក្រោកដើរម្តងៗ ដូច្នេះ ណានបានស្នើសុំរទេះសម្រាប់ជនពិការមួយគ្រឿងដើម្បីសម្រួលដល់ការធ្វើដំណើរ និងស្នើសុំវ៉ែនតាពាក់ព្រោះភ្នែករបស់គាត់មើលមិនច្បាស់ឡើយ។



លោកយាយ សឿ ណាន និងអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តតាកែវឈ្មោះ សៀង កញ្ញា។
(សៀង កញ្ញា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឯកអគ្គរដ្ឋទូតហ្វីលីពីនទស្សនកិច្ចតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង

មេក ទិន



លោក ឆាំង យុ ធ្វើបទបង្ហាញទាក់ទងផែនទី នៃស្រុកអន្លង់វែង ដល់លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន និងគណៈប្រតិភូ នៅការិយាល័យរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅជាប់ស្ពានអូរជីក ក្នុងស្រុកអន្លង់វែង។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន, លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅទីតាំងបូជាសព ប៉ុល ពត។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន និងគណៈប្រតិភូ បានធ្វើដំណើរទៅទស្សនារូងលាក់ខ្លួន ប៉ុល ពត នៅក្បាលទន្សោងដែលមានទីតាំងស្ថិតនៅលើភ្នំដងរែក និងមានចម្ងាយ២៨គីឡូម៉ែត្រពីរង្វង់មូលនៃស្រុកអន្លង់វែង។ (ឆាំង យុ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាព្រឹកថ្ងៃសៅរ៍ ទី២៦ ខែកុម្ភៈ ឆ្នាំ២០២២នេះ លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីនប្រចាំនៅប្រទេសកម្ពុជា បានធ្វើដំណើរមកកាន់តំបន់ប្រវត្តិសាស្ត្រក្នុងស្រុកអន្លង់វែងជាលើកដំបូង។

នៅវេលាម៉ោង៨:០០នាទីព្រឹក លោកជំទាវឯកអគ្គរដ្ឋទូត និងអនុព័ន្ធយោធាហ្វីលីពីនបានមកដល់ការិយាល័យរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។

បន្ទាប់មក បណ្ឌិត លី សុខឃាង ធ្វើបទបង្ហាញអំពីផែនការសកម្មភាពរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែនទីប្លង់គោលក្នុងស្រុកអន្លង់វែង និងបង្ហាញពីគម្រោងធ្វើរបងតាមបណ្តោយជួរភ្នំដងរែក។

បន្ទាប់មក គណៈប្រតិភូនៃដំណើរទស្សនកិច្ចនេះបានធ្វើដំណើរទៅកាន់ផ្ទះលាក់ខ្លួន ប៉ុល ពត និង ខៀវ សំផន នៅក្បាលទន្សោងដែលមានទីតាំងស្ថិតនៅលើភ្នំដងរែក និងមានចម្ងាយ២៨គីឡូម៉ែត្រពីរង្វង់មូលនៃស្រុកអន្លង់វែង។ នៅតាមដងផ្លូវមានទេសភាពស្រស់ត្រកាល ដែលរំលេចដោយព្រៃឈើ និងអាងស្តុបទឹកជាច្រើនកន្លែងដែលបន្សល់ទុកតាំងពីជំនាន់ខ្មែរក្រហម។ ក្រៅពីទេសភាពព្រៃឈើ ក៏ឃើញចម្ការដំណាំពណ៌បៃតងស្រស់ត្រកាលរបស់អ្នកភូមិ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជានៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ ផ្ទះលាក់ខ្លួនរបស់ ប៉ុល ពត ត្រូវបានសាងសង់ឡើងក្នុងឆ្នាំ១៩៩៣ បន្ទាប់ពីមេដឹកនាំខ្មែរក្រហមបានជ្រើសរើសទីសំចតចុងក្រោយ និងជាទីតាំងយុទ្ធសាស្ត្រសង្គ្រាមរបស់ខ្លួន។ គណៈប្រតិភូនៃដំណើរទស្សនកិច្ចនេះ ក៏បានធ្វើដំណើរចូលទៅក្នុងរូងលាក់ខ្លួន ប៉ុល ពត។ លោកជំទាវឯកអគ្គរដ្ឋទូត បានស្វែងយល់អំពីប្រវត្តិសាស្ត្រនៃចលនាលាក់ខ្លួន និងសង្គ្រាមទ័ពព្រៃនៅពេលដែលតំបន់អន្លង់វែងបានក្លាយជាទីតាំងចុងក្រោយរបស់ខ្មែរក្រហម។

គណៈប្រតិភូនៃដំណើរ ទស្សនកិច្ចនេះក៏បានត្រឡប់មកកាន់អតីតផ្ទះប្រជុំរបស់ តាម៉ុក ដែលស្ថិតនៅលើខ្នងភ្នំដងរែក ដែលបច្ចុប្បន្ននេះបានប្រែក្លាយទៅជាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ផ្ទះនេះត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៩៥ សម្រាប់ការជួបប្រជុំមេដឹកនាំខ្មែរក្រហមដូចជា ប៉ុល ពត, ខៀវ សំផន, នួន ជា, សុន សេន និងមេបញ្ជាការកងពលមួយចំនួនទៀត។

ទីតាំងបូជាសព ប៉ុល ពត គឺជាចំណុចទីបីនៃដំណើរទស្សនកិច្ចនេះ។ នៅពេលនោះ លោកជំទាវឯកអគ្គរដ្ឋទូតក៏បានស្តាប់ពីការរៀបរាប់ប្រវត្តិសាស្ត្រ រាប់ចាប់តាំងពីការកាត់ទោស ប៉ុល ពត ដោយ





លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន ព្រមទាំងគណៈប្រតិភូ និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាទស្សនារូងលាក់ខ្លួន ប៉ុល ពត នៅក្បាលទន្សោងដែលមានទីតាំងស្ថិតនៅលើភ្នំដងរែក និងមានចម្ងាយ២៨គីឡូម៉ែត្រពីរង្វង់មូលនៃស្រុកអន្លង់វែង។
(ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន ព្រមទាំងគណៈប្រតិភូ និង លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាទស្សនារូងលាក់ខ្លួន ប៉ុល ពត នៅក្បាលទន្សោងដែលមានទីតាំងស្ថិតនៅលើភ្នំដងរែក និងមានចម្ងាយ២៨គីឡូម៉ែត្រពីរង្វង់មូលនៃស្រុកអន្លង់វែង។
(ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)




*លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីន (រូបទី៨រាប់ពីស្តាំ) ព្រមទាំងគណៈប្រតិភូ និង លោក ឆាំង យុ (រូបទី៣រាប់ពីស្តាំ) និងក្រុមការងារនៅ ខាងមុខការិយាល័យរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅជាប់ស្ពានអូរជីក ក្នុងស្រុកអន្លង់វែង។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

តុលាការប្រជាជន និងគម្រោងសាងសង់ដំបូលផ្ទះ ប៉ុល ពត ដែលនឹងចាប់ផ្តើមនាពេលខាងមុខទៀតផង។ ការសន្ទនារវាងលោកជំទាវឯកអគ្គរដ្ឋទូតហ្វីលីពីន និងនាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានចំណាយពេលប្រមាណ៣០នាទី។

នៅវេលាម៉ោង ២ រសៀល លោកជំទាវ ម៉ារី អាមេលីតា អាគីណូ ឯកអគ្គរដ្ឋទូតហ្វីលីពីនប្រចាំនៅប្រទេសកម្ពុជា និងអនុព័ន្ធយោធា ហ្វីលីពីន ទៅជួបសម្តែងការគួរសមឯកឧត្តម នាយឧត្តមសេនីយ៍ គន់ គីម ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និងប្រធានអនុគណៈកម្មការសាងសង់«ស្តូបឈ្នះ ឈ្នះ អន្លង់វែង»។

បន្ទាប់មក គណៈប្រតិភូនៃដំណើរទស្សនកិច្ចនេះ បានបន្តដំណើរមកកាន់សារមន្ទីរ តាម៉ុក ឬអតីតផ្ទះតាម៉ុក ដែលបានសាងសង់ឡើងនៅក្នុងឆ្នាំ១៩៩៣។ បច្ចុប្បន្ននេះអតីតផ្ទះតាម៉ុក គឺជាទីកន្លែងដ៏សំខាន់មួយនៅក្នុងស្រុកអន្លង់វែងដែលអាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនា។

ជាកិច្ចបញ្ចប់លោកជំទាវឯកអគ្គរដ្ឋទូតហ្វីលីពីន រួមទាំងអនុព័ន្ធយោធា សម្តែងនូវសេចក្តីសោមនស្សរីករាយចំពោះការទទួលស្វាគមន៍លោកជំទាវមកកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង។

# រឿងរ៉ាវរបស់ ឯម ម៉ើ ក្នុងរបបខ្មែរក្រហម

*ឈុំ រ៉ា*




*ឯម ម៉ើ អាយុ៩១ឆ្នាំ និងភរិយាកំពុងផ្តល់បទសម្ភាសន៍ដល់ក្រុមការងាររមជ្ឈមណ្ឌលឯកសារ កោះថ្មៗ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ឯម ម៉ើ ភេទប្រុស កើតនៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣១បានរៀបរាប់ថា ខ្ញុំមានបងប្អូនចំនួន៧ នាក់ (ប្រុស៦នាក់ និងស្រី១នាក់) ហើយខ្ញុំគឺជាកូនច្បង។ ខ្ញុំមានម្តាយឈ្មោះ ឡូ ឈុនបានស្លាប់ តាំងពីខ្ញុំមានអាយុ១២ឆ្នាំ ចំណែកឪពុកឈ្មោះ ឯម។ ម្តាយឪពុករបស់ខ្ញុំគឺជាជនជាតិខ្មែរ មានស្រុកកំណើតនៅភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ (កាលពីមុនខេត្តកំពង់ចាម)។ កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រច្រើនទេ។ បងប្រុសរបស់ខ្ញុំបានជំរុញឲ្យខ្ញុំចូលរៀនដែរ ប៉ុន្តែខ្ញុំមិនចង់បែកពីម្តាយ។ កាលពីតូចខ្ញុំគ្មានសម្លៀកបំពាក់ទេ ខ្ញុំបានយកសម្បកឈើមកដំឲ្យទន់ដើម្បីបាំងខ្លួន។ នៅពេលខ្ញុំអាយុ១១ឆ្នាំ ខ្ញុំបានចូលរៀននៅវត្តក្រវៀន។ ខ្ញុំរៀនបានរយៈពេលបួនឆ្នាំ ព្រះចៅអធិការវត្តឈ្មោះ វែង បានឲ្យខ្ញុំបួស។ ខ្ញុំបានរៀនធម៌វិន័យ និងរៀនអក្សរសាស្ត្រ ពីគ្រូ អ៊ុង, គ្រូ វែង និង គ្រូជឹង។ អំឡុងពេលដែលសិក្សានៅក្នុងវត្តគឺ មានសិស្សចំនួន៤០នាក់ នៅក្នុងនោះមានសិស្សស្រីចំនួន៥ នាក់តែប៉ុណ្ណោះ។ កាលពីសង្គមចាស់ ប្រជាជនមិនសូវឲ្យកូនស្រីសិក្សារៀនសូត្រទេ ព្រោះខ្លាចកាលណាកូនស្រីមានចំណេះដឹងច្រើន គឺចេះសរសេរសំបុត្រស្នេហា។ ខ្ញុំបួសបានរយៈពេល៨វស្សា គឺបួសសាមណេរបានរយៈពេល៥ព្រះវស្សា និងបួសភិក្ខុបានរយៈពេល

៣វស្សា។ ក្រោយមក ខ្ញុំបានសឹកមកប្រកបរបរធ្វើស្រែចម្ការវិញ។ ក្រោយពីសឹករួច មេឃុំហៅខ្ញុំទៅឲ្យជួយសរសេររបាយការណ៍ជំនួសស្មៀន ព្រោះស្មៀនមិនសូវធ្វើការ ហើយផឹកស្រា។ ខ្ញុំបានធ្វើការជំនួសស្មៀនអស់រយៈពេលបីខែ ក៏សុំមេឃុំមកលេងផ្ទះ ព្រោះអត់មានអ្នកជួយធ្វើការងារជំនួសឪពុកម្ដាយ។ កាលពីសង្គមចាស់ នៅក្នុងភូមិសាទុំមានផ្លូវតែមួយខ្សែប៉ុណ្ណោះ។ ដំបូងបារាំងបានចូលមកដាំដើមកៅស៊ូនៅក្រឡុងសិទ្ធិ និងខ្លាយ ដែលមានកម្មករជាជនជាតិខ្មែរ និងជនជាតិវៀតណាម។ ឪពុករបស់ខ្ញុំមានចំណេះដឹង ដូច្នេះខាងរាជការឲ្យគាត់វាស់វែងដីធ្លីសម្រាប់ធ្វើផ្លូវ។ នៅសង្គមចាស់អ្នកចេះដឹង ជនជាតិបារាំងហៅឈ្មោះថា ជី។ បារាំងបានធ្វើផ្លូវពីស្រុក ឡុកនិញទៅព្រៃនគរ និងភ្ជាប់មកភូមិសាទុំ ភូមិប្រិយ៍, អូរអង្កាម, ក្រឡុងសិទ្ធិរហូតទៅដល់មេមត់។ កាលពីដើមប្រជាជននៅក្នុងភូមិសាទុំមិនហ៊ានចូលព្រៃទេព្រោះខ្លាចសត្វខ្លា និងដំរី។ ខ្ញុំបានជួបសម្ដេចព្រះ នរោត្តម សីហនុម្ដង ពេលដែលទ្រង់ចុះមកដល់ស្រុកមេមត់។ កាលពីដើម នៅក្នុងភូមិសាទុំ មានផ្ទះចំនួន១៧ ខ្នងតែប៉ុណ្ណោះ។ ភូមិសាទុំក្លាយមកពីរឿងដំណាល «ស្រីយំ» ព្រោះមានស្រីម្នាក់ដើរមកពីខាងភូមិព្រៃ ប៉ុន្តែដោយសារចុកជើងខ្លាំងពេកក៏អង្គុយយំ។ ក្រោយមកដោយសារអ្នកស្រុកនិយាយមិនច្បាស់ ក៏បាននិយាយតៗគ្នាថា «សាទុំ» ។ ប្រជាជនខ្លះហៅភូមិនេះថា «ស្ទុំ»។ ចំណែកប្រជាជនខ្លះទៀតដំណាលថា ពីដើមមានសត្វបក្សីជាច្រើនហើរមកទុំលើដើមពោធិ៍ ហើយក៏ហើរត្រឡប់ទៅវិញ ទើបអ្នកភូមិនាំគ្នាហៅថា «ស្រទុំ» ជាប់មក ។

កាលពីសម័យបារាំង ប្រជាជននាំគ្នាវេចខោអាវត្រៀមរួចជាស្រេច ហើយពេលឮសំឡេងគ្រាប់កាំភ្លើងម្ដងៗក៏នាំគ្នាចូលរត់ពួននៅក្នុងព្រៃព្រោះខ្លាចចោរប្លន់។ ខ្ញុំដឹងថាចោរទាំងអស់នោះមានខ្មែរ និងវៀតណាមខ្លះ។ បារាំងបានយកជនជាតិវៀតណាមមកពីហាណូយមកចៀរជ័រកៅស៊ូ ជំនួសឲ្យជនជាតិខ្មែរ ព្រោះបារាំងប្រើខ្មែរមិនបាន។ នៅពេលដែលខ្ញុំពេញកំលោះ ខ្ញុំសុំម្ដាយរៀបការជាមួយនារីម្នាក់ដែលខ្ញុំស្រឡាញ់នៅក្នុងភូមិ ប៉ុន្តែដំបូងម្ដាយរបស់ខ្ញុំបដិសេធ។ ខ្ញុំនៅតែចចេសចង់រៀបការជាមួយនារីនោះដដែលដែលត្រូវជាកូនស្រីរបស់ប៉ូលីសឈ្មោះ ឡឹក និងប្រពន្ធឈ្មោះ យ៉ុង។ ក្រោយមក ខ្ញុំបានរៀបការជាមួយនារីនោះបានកូនពីរនាក់ ហើយកូនម្នាក់បានស្លាប់នៅក្នុងសម័យខ្មែរក្រហម។ ដោយសារតែយើងរស់នៅមិនចុះសម្រុងនឹងគ្នា ខ្ញុំបាននិយាយជាមួយប្រពន្ធរបស់ខ្ញុំថា បើយើងមិនស្រឡាញ់គ្នាទេយើងលែងគ្នា។ ក្រោយពេលខ្ញុំបានលែងលះជាមួយប្រពន្ធដើមរួចរាល់ហើយ ខ្ញុំបានរៀបការជាមួយប្រពន្ធក្រោយឈ្មោះ ឆន និងមានកូនចំនួន៧ នាក់។ ក្រោយមក ប្រពន្ធក្រោយរបស់ខ្ញុំពិការដៃម្ខាងដោយសារពស់ចឹក។

នៅពេលមានបាតុកម្មទម្លាក់សម្ដេចសីហនុ ខ្ញុំចាប់ផ្ដើមរកស៊ីលក់ដូរអង្ករ។ ខ្ញុំធាក់កង់ដឹកអង្ករពីមេមត់យកទៅលក់ឲ្យកងទ័ពវៀតណាម។ ខ្ញុំដឹកអង្ករម្ដងបាន២០គីឡូក្រាម ហើយក្នុងមួយគីឡូក្រាម ខ្ញុំចំណេញមួយរៀល។ នៅពេលយប់ខ្ញុំមិនសូវបានដេកទេ ព្រោះត្រូវចេញទៅដឹកអង្ករយកទៅលក់ឲ្យកងទ័ពវៀតកុង។ ខ្ញុំដឹកជញ្ជូនអង្ករឲ្យកងទ័ពវៀតកុងនៅម្ដុំត្រពាំងតាហត និងត្រពាំងឈើខ្ទិម។ កាលនោះមានអ្នកដឹកអង្ករលក់ច្រើននាក់ មកពីឃុំជាំក្រវៀន។ ខ្ញុំលក់អង្ករគិតជាលុយខ្មែរ ហើយមេការដែលរង់ចាំទិញអង្ករឈ្មោះ សៅ ភុក។ ដោយសារតែមានសង្គ្រាមរវាងអាមេរិកាំង និងកងទ័ពវៀតកុង ខ្ញុំមិនបានចាយលុយទេ ហើយក្របីញីរបស់ខ្ញុំមួយក្បាល និងក្របីឈ្មោលមួយក្បាល លក់បានត្រឹមតែ ១០០០ រៀលតែប៉ុណ្ណោះ។

កងទ័ពវៀតកុងបានសង់មន្ទីរពេទ្យនៅក្នុងព្រៃកាដូនម៉ាច និងព្រៃតាសឹង។ នៅមន្ទីរពេទ្យនោះគឺមានផ្នែកវះកាត់ដែលប្រើឧបករណ៍ទំនើបៗ។ កងទ័ពវៀតកុងបានជួលខ្មែរឲ្យជួយបកប្រែ ហើយកងទ័ពវៀតកុងខ្លះអាចនិយាយភាសាខ្មែរបានប៉ុន្តែមិនសូវច្បាស់។ ខ្ញុំបានយកម្ដាយក្មេករបស់ខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យរបស់វៀតកុង ក្រោយមកម្ដាយក្មេករបស់ខ្ញុំបានជាសះស្បើយឡើងវិញ។ ក្រោយពេល

យោធាអាមេរិកស៊ើបដឹងថាមានកងទ័ពវៀតកុង ទើបមានការទម្លាក់គ្រាប់បែកដើម្បីសម្លាប់កងទ័ពវៀតកុងៗ គ្រាប់បែកបេ-៥២ ជាច្រើនគ្រាប់បានផ្ទុះរង្គើរដល់ផ្ទះប្រជាជនដែលរស់នៅក្នុងភូមិសាទុំ និងផ្ទះខ្លះដែលប្រក់ស្លឹកទ្រាំងបានរបើកដំបូលៗ នៅវេលាម៉ោង៩ល្ងាច មានការទម្លាក់គ្រាប់លើទីជម្រកកងទ័ពវៀតកុង បណ្តាលឲ្យកងទ័ពវៀតកុង និងប្រជាជនមួយចំនួនបានស្លាប់ ហើយប្រជាជននៅក្នុងភូមិសាទុំមួយចំនួនទៀតរងរបួសៗ នៅអំឡុងពេលសង្គ្រាមរវាងអាមេរិក និងកងទ័ពវៀតកុងបានផ្ទុះឡើង ប្រជាជននៅក្នុងភូមិសាទុំ បានភៀសខ្លួនទៅរស់នៅភូមិដាំក្រវៀន និងភូមិដូងៗ នៅពេលចប់សង្គ្រាម ទើបប្រជាជននាំគ្នាមករស់នៅក្នុងភូមិវិញៗ

នៅសម័យខ្មែរក្រហម ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិសាទុំឲ្យទៅនៅភូមិខ្នុរៗ ខ្មែរក្រហមចាត់តាំងឲ្យខ្ញុំនៅកងសិប្បកម្ម ធ្វើនង្គ័ល និងរនាស់ៗ ចំណែកប្រពន្ធកូនរបស់ខ្ញុំនៅក្នុងភូមិសាទុំដដែលៗ មិនយូរប៉ុន្មានខ្មែរក្រហមបានជម្លៀសប្រពន្ធរបស់ខ្ញុំឲ្យមករស់នៅភូមិខ្នុរជាមួយខ្ញុំដែរៗ ប្រធានកងបានចាត់តាំងខ្ញុំឲ្យទៅរកត្រី និងសាច់មកដាក់នៅក្នុងសហករណ៍ ចំណែកប្រពន្ធរបស់ខ្ញុំប្រធានកងចាត់តាំងឲ្យទៅស្ទូងស្រូវ និងធ្វើស្រែៗ មួយឆ្នាំក្រោយមកខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំឲ្យទៅនៅភូមិតាអឹម ឃុំដាំតាម៉ៅ ស្រុកមេមត់ វិញៗ នៅទីនោះ ខ្ញុំធ្វើស្រែលើកប្រព័ន្ធភ្លឺស្រែ និងជីកប្រឡាយៗ តមក ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅនៅសហករណ៍ ក្នុងស្រុកឆ្លូង ខេត្តក្រចេះៗ ប្រធានសហករណ៍បានចោទប្រកាន់ខ្ញុំថា លួចក្របី ហើយយកកាំភ្លើងមកភ្ជង់ក្បាលខ្ញុំៗ ប្រធានសហករណ៍យកខ្ញុំទៅឃុំរយៈពេលមួយយប់ៗ ខ្ញុំបាននិយាយថា ខ្ញុំមិនបានធ្វើអ្វីខុសនោះទេ ប្រសិនបើមិត្តសម្លាប់ខ្ញុំក៏ខ្ញុំមិនខ្លាចស្លាប់ដែរៗ ព្រឹកឡើងប្រធានសហករណ៍ដោះលែងឲ្យខ្ញុំត្រឡប់មកផ្ទះវិញ ហើយបន្ទាប់មកបានចាត់តាំងខ្ញុំឲ្យបររទេះដឹកសំណាបៗ ចំណែកកូនរបស់ខ្ញុំប្រធានកងប្រើឲ្យរើសអាចម៍គោដើម្បីធ្វើជីៗ ចំពោះម្ហូបអាហារ គឺមានតែបបរប៉ុណ្ណោះ ហើយខ្ញុំហូបមិនដែលឆ្អែតទេៗ ថ្ងៃមួយ ខ្ញុំបានបររទេះទៅដឹកសំណាបឲ្យអ្នកស្ទូងៗ ខ្ញុំគិតក្នុងចិត្តថាប្រសិនបើខ្ញុំមិនលួចច្បាស់ជាដាច់ពោះស្លាប់មិនខាន ដូច្នេះខ្ញុំបានយកផ្លែសណ្តូចលាក់ទុកនៅក្នុងហោប៉ៅខោៗ នៅពេលខ្ញុំទៅដល់បឹង ខ្ញុំយកផ្លែសណ្តូចចេញពីហោប៉ៅដើម្បីស្ទូចត្រីៗ ក្រុមដឹកសំណាបរបស់ខ្ញុំមានគ្នាបួននាក់ ដូច្នេះខ្ញុំនិយាយប្រាប់អ្នកនៅក្នុងក្រុមថាប្រសិនបើយើងចង់ហូបឆ្អែតយើងកុំរាយការណ៍ឲ្យអ្នកផ្សេងដឹងៗ នៅថ្ងៃនោះយើងស្ទូចបានត្រី និងបានហូបឆ្អែតៗ ខ្ញុំបានលួចខ្ចប់ត្រីយកទៅឲ្យប្រពន្ធនិងកូនរបស់ខ្ញុំនៅផ្ទះថែមទៀតៗ នៅទីនោះ ឪពុកក្មេករបស់ខ្ញុំបានស្លាប់ដោយសារអត់អាហារៗ ក្រោយមកទៀត ខ្មែរក្រហមឲ្យខ្ញុំធ្វើជាជាងឈូសឈើ និងសសរផ្ទះៗ មេកងបានកំណត់ឲ្យខ្ញុំឈូសសសរផ្ទះឲ្យបាន ២ទៅ៣ដើម ក្នុងមួយថ្ងៃៗ ប្រសិនបើខ្ញុំឈូសមិនហើយ អង្គការនឹងយកខ្ញុំទៅរៀនសូត្រៗ ខ្ញុំរស់នៅក្នុងសហករណ៍ក្នុងស្រុកឆ្លូងរយៈពេលមួយឆ្នាំ ទើបខ្មែរក្រហមជ្រើសរើសខ្ញុំឲ្យទៅនៅស្រែរនាម ឃុំឃ្សឹម ស្រុកឈ្លូល ខេត្តក្រចេះវិញៗ នៅថ្ងៃនោះ ខ្មែរក្រហមបានជជែកគ្នាថានឹងបើករថយន្តទៅក្រុងក្រចេះទាំងយប់ៗ ក្រោយពេលខ្ញុំស្តាប់ឮដំណឹងនេះ ខ្ញុំជាមួយកូនៗនិងប្រពន្ធខ្ញុំលួចឡើងជិះរថយន្តខ្មែរក្រហមនោះៗ ព្រឹកឡើងខ្ញុំនិងគ្រួសារបានចុះពីលើឡាន ឃើញដូច្នេះអ្នកបើករថយន្តបានសួរថាខ្ញុំ តើលោកពូឡើងជិះលើឡានតាំងពីពេលណាៗ ខ្ញុំបានប្រាប់តាមត្រង់ថា លួចឡើងតាំងពីយប់មិញម៉្លេះ បន្ទាប់មកខ្មែរក្រហមបានសួរខ្ញុំថា តើលោកពូចង់ទៅណា? ខ្ញុំបានឆ្លើយថាខ្ញុំមិនដឹងទៅណាទេៗ ខ្មែរក្រហមបាននាំខ្ញុំទៅរកកន្លែងសម្រាក និងឲ្យអង្ករមកខ្ញុំដើម្បីដាំបាយហូបៗ នៅថ្ងៃបន្ទាប់ ខ្ញុំនិងគ្រួសារបានដើររហូតទៅដល់ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះៗ នៅទីនោះខ្ញុំឃើញយោធា និងត្រីងៀតជាច្រើនៗ ដោយសារតែខ្ញុំឃ្លានខ្លាំងពេក ទើបខ្ញុំដាច់ចិត្តសុំត្រីងៀតពីយោធាយកមកហូបៗ នៅខណៈនោះប្រធានសហករណ៍ថ្មគ្រែបានសួរខ្ញុំថា លោកពូមកពីណា? ខ្ញុំឆ្លើយថា ខ្ញុំមិនដឹងមកពីណាទេព្រោះជិះឡានពេល

យប់ៗ ខ្ញុំនិយាយទៅកាន់ប្រធានសហករណ៍ថា បើមិត្តចង់សម្លាប់ខ្ញុំក៏សម្លាប់ចុះៗ ប៉ុន្តែប្រធានសហករណ៍មិនបានធ្វើបាបខ្ញុំទេ ហើយបានចាត់តាំងខ្ញុំទៅធ្វើសម្បុកមាន់ៗ ដោយសារតែឃ្លានខ្លាំងពេក ខ្ញុំបានលួចពងមាន់នៅក្នុងសម្បុកមួយគ្រាប់ៗ ពេលនោះខ្ញុំបេះដាងឈើ ដូច្នេះប្រធានសហករណ៍ឲ្យខ្ញុំធ្វើដាងសង់ផ្ទះៗ ថ្ងៃមួយ មានអ្នកឃុំលគោម្នាក់បានប្រាប់ខ្ញុំថា នៅផ្ទះដែលខ្ញុំរស់នៅមានមនុស្សស្លាប់ទាំងគ្រួសារ ឪពុកម្តាយ និងកូន គឺស្លាប់ដោយសារលេបថ្នាំព្រោះតែស្តាយទ្រព្យសម្បត្តិៗ អ្នកឃុំលគោបានសួរខ្ញុំថា ខ្លាចខ្មោចដែរឬទេ? ខ្ញុំឆ្លើយថាស្លាប់ហើយគ្មានអ្វីត្រូវខ្លាចឡើយៗ មិនបានប៉ុន្មានថ្ងៃផង ខ្មែរក្រហមជម្លៀសខ្ញុំតាមកាណូតទៅស្រុកស្ទឹងត្រង់ បន្ទាប់មកជិះឡានបន្តទៅភូមិតាអុង ឃុំតាអុង ស្រុកចំការលើ ដោយគ្មានបាយហូបឡើយ គឺយើងហូបបាយលាយពេកៗ ខ្មែរក្រហមបានប្រើខ្ញុំឲ្យរែកទឹក ជីកដី ធ្វើដី ដើម្បីស្រោចស្លែ ប៉ុន្តែដោយសារតែខ្ញុំអត់បាយយូរថ្ងៃទើបខ្ញុំគ្មានកម្លាំងរែកទឹកៗ ខ្ញុំរស់នៅទីនោះបានកន្លះខែ កងទ័ពវៀតណាមចូលមកដល់ ហើយយើងក៏ធ្វើដំណើរដោយថ្មើរជើងមកស្រុកកំណើតវិញៗ ពេលខ្ញុំមកក្រុងសួង ខ្ញុំដើររើសក្ដួរស្រូវ រួចបន្តដំណើរមករស់នៅក្នុងភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ រហូតមកដល់សព្វថ្ងៃៗ

សាលាឃុំជាំក្រវៀន ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំៗ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



# ឯកអគ្គរដ្ឋទូតសិង្ហបុរីទស្សនកិច្ចតំបន់អន្លង់វែង

*រមក ខិន*



លោកជំទាវ គ្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសារមន្ទីរផ្ទះ តាម៉ុក។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ លោកជំទាវ គ្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញមកធ្វើទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនៃស្រុកអន្លង់វែងជាទីដែលសង្គ្រាមត្រូវបានបញ្ចប់ និងសន្តិភាពចាប់ផ្តើមកើតមានឡើងវិញ។ លោកជំទាវឯកអគ្គរដ្ឋទូតបានក្លាយទៅជាអ្នកការទូតទីពីរនៃបណ្តាប្រទេសអាស៊ានដែលបានអញ្ជើញមកដល់តំបន់អន្លង់វែង ខណៈដែលប្រទេសកម្ពុជាកំពុងធ្វើជាប្រធានប្តូរវេនរបស់អាស៊ាន។

នៅវេលាម៉ោង៨:០០នាទីព្រឹក លោកជំទាវឯកអគ្គរដ្ឋទូតបានមកដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដោយទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ នៅក្នុងដំណើរទស្សនកិច្ចនេះ លោកជំទាវ

លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅសារមន្ទីរផ្ទះ តាម៉ុក។
ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញមកធ្វើទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនៃស្រុកអន្លង់វែង ដោយទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពី លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានគោលបំណងស្វែងយល់ពីតំបន់ប្រវត្តិសាស្ត្រអន្លង់វែងដែលជាទីតាំងតស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហម។ ស្រុកអន្លង់វែង មានទីតាំងប្រវត្តិសាស្ត្រចំនួន១៨កន្លែងដែលបម្រើឲ្យគោលដៅទេសចរណ៍ជាតិ និងអន្តរជាតិ។

នៅក្នុងឱកាសនៃដំណើរទស្សនកិច្ចរបស់លោកជំទាវអគ្គរដ្ឋទូតនេះ បណ្ឌិត លី សុខឃាង ក៏បានបង្ហាញអំពីកិច្ចការងារមួយចំនួនទាក់ទងនឹងការបង្កើតវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

បន្ទាប់មក លោកជំទាវឯកអគ្គរដ្ឋទូត បានធ្វើដំណើរឆ្ពោះទៅកាន់អតីតផ្ទះប៉ុល ពត និងខៀវ សំផន, អតីតផ្ទះប្រជុំរបស់ តាម៉ុក នៅលើភ្នំដងរែក និងសារមន្ទីរផ្ទះ តាម៉ុក។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសាកម្ពុជា បានរៀបរាប់យ៉ាងក្បោះក្បាយអំពីទីតាំងប្រវត្តិសាស្ត្រនីមួយៗ និងបានផ្តោតការពិភាក្សាអំពីពាក្យ «សន្តិភាព» ដែលប្រទេសកម្ពុជាបានទទួលនាពេលបច្ចុប្បន្ន។

ឧត្តមសេនីយ៍ត្រី និត ណារ៉ុង ក៏បានចូលរួមធ្វើអត្ថាធិប្បាយអំពីរឿងរ៉ាវប្រវត្តិសាស្ត្រនៃការធ្វើសង្គ្រាមនៅ

*តំបន់អន្លង់វែង និងការសម្រេចបាននូវសន្តិភាពក្រោមគោលនយោបាយ ឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាលកម្ពុជា។ បច្ចុប្បន្ននេះ អន្លង់វែងចាប់ផ្តើមបោះជំហានទៅរកការប្រែមុខមាត់ថ្មីតាមរយៈការសាងសង់«ស្តូប ឈ្នះ ឈ្នះ អន្លង់វែង»។ មុនពេលវិលត្រឡប់មកវិញ លោកជំទាវឯកអគ្គរដ្ឋទូត ត្យូ ឡេឆេង សម្តែងនូវការកោតសរសើរចំពោះដំណើរទស្សនកិច្ចសិក្សាស្វែងយល់អំពីសង្គ្រាម និងសន្តិភាពនៅប្រទេសកម្ពុជា ព្រមទាំងបេសកកម្មរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក្នុងការអប់រំយុវជនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។*



*លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅពើយ តាម៉ុក។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*




*លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅកន្លែងលាក់ខ្លួនរបស់ ប៉ុល ពត នៅក្បាលទន្សោង។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



*លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅកន្លែងលាក់ខ្លួនរបស់ ប៉ុល ពត នៅក្បាលទន្សោង។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*





លោកជំទាវ គ្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅរូងលាក់ខ្លួនរបស់ ប៉ុល ពត នៅក្បាលទន្សោងៗ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ គ្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ទស្សនកិច្ចទីតាំងបូជាសព ប៉ុល ពត នៅលើភ្នំដងរែកៗ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដំណើរទស្សនកិច្ចរួមគ្នារបស់ឯកអគ្គរាជទូតអង់គ្លេស និងឯកអគ្គរដ្ឋទូតឥណ្ឌា

## មកកាន់បណ្ណាល័យសម្តេចម៉ែ

**ដារ៉ាវដ្ឋ មេត្តា**



លោកជំទាវវេជ្ជបណ្ឌិត ដេវ៉្យានី ខុប្រាហ្គឹដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា, យុវតី លេខ ការី មានតួនាទីជាអ្នកដើរតួនាទីជំនួសលោកជំទាវវេជ្ជបណ្ឌិត ដេវ៉្យានី ខុប្រាហ្គឹដេ របស់ឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅបណ្ណាល័យ «សម្តេចម៉ែ»។
ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។
( ដារ៉ាវដ្ឋ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ លោកជំទាវ ធីណា រ៉ែដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវវេជ្ជបណ្ឌិត ដេវ៉្យានី ខុប្រាហ្គឹដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា រួមជាមួយ យុវតី ហឿង ហ្គិច លីម មានតួនាទីជាអ្នកដើរតួនាទីជំនួសលោកជំទាវ ធីណា រ៉ែដស របស់អង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង យុវតី លេខ ការី មានតួនាទីជាអ្នកដើរតួនាទីជំនួសលោកជំទាវវេជ្ជបណ្ឌិត ដេវ៉្យានី ខុប្រាហ្គឹដេ របស់ឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អញ្ជើញមកធ្វើទស្សនកិច្ចរួមគ្នានៅបណ្ណាល័យសម្តេចម៉ែ។

ស្ថានទូតអង់គ្លេសបានចាប់ផ្តើមការប្រកួតប្រជែង «ឯកអគ្គរាជទូតមួយថ្ងៃ» ដើម្បីស្នើឲ្យបេក្ខជនជាស្ត្រីវ័យក្មេងចូលរួមផលិតវីដេអូផ្ទាល់ខ្លួនក្នុងគោលបំណងពិភាក្សា និងលើកកម្ពស់ការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងកុមារ, ផ្តល់ឱកាស

ឲ្យសម្រេចបានការងារក្នុងក្តីស្រមៃរបស់ខ្លួននៅឆ្នាំ ២០៣០។ យុវតី ហឿន ហ៊ុច លីម គឺជាអ្នកឈ្នះនៅក្នុងកម្មវិធីប្រកួតប្រជែងនេះ ដែលនឹងចំណាយពេលមួយថ្ងៃជាមួយឯកអគ្គរាជទូតអង់គ្លេស ធីណា រ៉េដស នៅក្នុងព្រឹត្តិការណ៍ណាមួយ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២២ នេះ។ ស្ថានទូតឥណ្ឌា ក៏មានយុវតី លេខ ការី ដែលជាអ្នកឈ្នះក្នុងការប្រកួតប្រជែង «ឯកអគ្គរាជទូតមួយថ្ងៃ» នេះដែរ ទោះបីដំណើរការជ្រើសរើសអ្នកឈ្នះខុសពីគ្នាក៏ដោយ។

ឯកអគ្គរដ្ឋទូតទាំងពីររូបដែលជាប់ក្នុងការប្រកួតប្រជែង «ឯកអគ្គរាជទូតមួយថ្ងៃ» បានមកធ្វើទស្សនកិច្ចរួមគ្នានៅបណ្ណាល័យ «សម្តេចម៉ែ» នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ នេះ។ វាគឺជាព្រឹត្តិការណ៍រួមគ្នាលើកទីមួយអំពីប្រធានបទនេះ របស់ស្ថានទូតអង់គ្លេស និងស្ថានទូតឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

គណៈប្រតិភូ អញ្ជើញមកដល់បណ្ណាល័យសម្តេចម៉ែនៅវេលាម៉ោង៩:០០ព្រឹក ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីអ្នកស្រី សូ ហ្វារីណា នាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកស្រី សូ ហ្វារីណា ធ្វើការណែនាំនិងបង្ហាញអំពីប្លង់អគារស្ទីករីត ដែលកំពុងដាក់តាំងបង្ហាញនៅច្រកចូលបណ្ណាល័យ «សម្តេចម៉ែ»។ ប្លង់រចនាអគារស្ទីករីតនេះ គឺជាស្នាដៃរបស់ស្ថាបត្យករកម្រិតពិភពលោក គឺលោកស្រី ហ្សាហា ហាឌីដ ដែលមានភាពខុសប្លែកពីអគារបែបអភិរក្សនៃសំណង់ស្ថាបត្យកម្ម ដោយបម្រើនាទីជាបូជនីយដ្ឋានរំឭកអំពីអំពើប្រល័យពូជសាសន៍។ អគារស្ទីករីត ក៏ជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដើម្បីរំឭក និងឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតប្រមាណ ២ លាននាក់ ក្នុងអំឡុងរបបប្រល័យពូជសាសន៍ខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

នៅក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ អ្នកស្រី សូ ហ្វារីណា បង្ហាញសៀវភៅកំណត់ហេតុដ៏គួរឲ្យចាប់អារម្មណ៍របស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលមានចំណងជើងថា «ព្រះរាជដំណើររបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ យាងទៅកាន់តំបន់រំដោះនៃរណសិរ្សរួមជាតិកម្ពុជា ក្នុងឆ្នាំ១៩៧៣ ដល់គណៈប្រតិភូ។

ជាកិច្ចបន្ត លោកស្រី សូ ហ្វារីណា ដឹកនាំគណៈប្រតិភូទៅទស្សនាបន្ទប់រក្សាទុកឯកសារនៅបណ្ណាល័យ «សម្តេចម៉ែ» ដែលរួមមាន សៀវភៅរាប់ពាន់ក្បាល, ឯកសាររាប់លានទំព័រ, ឯកសារសំណៅដើម, បណ្ណសារជារូបថត និងវីដេអូ, បណ្ណសារសោតទស្សន៍ និង



លោកជំទាវ ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវវេជ្ជបណ្ឌិត ដេវ៉្យានី ខុប្រាហ្គឺដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា មកទស្សនកិច្ចនៅបណ្ណាល័យសម្តេចម៉ែ ដោយមានការទទួលស្វាគមន៍ពីលោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ ( ផាត ចាន់សុនិតា/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

*បរិក្ខារផ្ទុកឯកសារជាទម្រង់ឌីជីថល។ លោកស្រី សូ ហ្វារីណា ក៏បានលើកឡើងអំពីសាខារបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា ដែលមាននៅតាមបណ្តាខេត្តមួយចំនួន ដូចជា ខេត្តឧត្តរមានជ័យ, ព្រៃវែង, កំពង់ចាម, ត្បូងឃ្មុំ, តាកែវ និងពោធិ៍សាត់ដើម្បីបម្រើដល់ការស្រាវជ្រាវរបស់សាធារណជន។*

*លោកជំទាវឯកអគ្គរាជទូតអង់គ្លេស និងឯកអគ្គរដ្ឋទូតឥណ្ឌា បានសរសើរអំពីតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាបណ្ណាល័យសម្តេចម៉ែ ក្នុងការថែរក្សាឯកសារទុកសម្រាប់សាធារណជន និងបានរួមចំណែកផ្តល់ឯកសារដល់សាលាក្តីខ្មែរក្រហមដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ព្រមទាំងបានធ្វើការអប់រំអំពីរបបខ្មែរក្រហមដល់សិស្សានុសិស្សនិងយុវជនជំនាន់ក្រោយ។*

*ជាចុងក្រោយ គណៈប្រតិភូបានចំណាររនៅលើសៀវភៅក្រាំងមាសរបស់បណ្ណាល័យ «សម្តេចម៉ែ» ដែលមានខ្លឹមសារ ដូចតទៅ ៖*

**«នេះគឺជាលើកទីមួយសម្រាប់ខ្ញុំដែលបានមកទស្សនកិច្ចនៅបណ្ណាល័យ «សម្តេចម៉ែ»។ ខ្ញុំពិតជាមានសេចក្តីរីករាយ សោមនស្សយ៉ាងក្រៃលែងនៅពេលដែលបានស្តាប់នូវទីរភាពដ៏អង់អាចក្លាហានរបស់សម្តេចម៉ែ។ ប៉ុន្តែ ខ្ញុំហាក់ដូចជាមានអារម្មណ៍កម្សត់នៅពេលបានស្តាប់អំពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ខ្ញុំនឹងចងចាំនូវអនុស្សាវរីយ៍នៅថ្ងៃនេះហើយចែករំលែកឱ្យសហគមន៍ខ្ញុំបានដឹង»។**

— *យុវតី* **លេខ ការី** *មកពីខេត្តរតនគិរី*

**«ខ្ញុំពិតជាបានឃើញផ្ទាល់ភ្នែករបស់ខ្ញុំ។ វាគួរតែជាទីកន្លែងដែលអ្នកត្រូវតែមកទស្សនាម្តងក្នុងមួយជីវិតរបស់អ្នក។ ខ្ញុំបានស្តាប់នូវប្រវត្តិសាស្ត្ររបស់ជាតិខ្ញុំ»។**

— *យុវតី* **ហឿង ហ្គិច លីម** *មកពីទីក្រុងភ្នំពេញ*



*គណៈប្រតិភូកំពុងស្តាប់លោកស្រី សូ ហ្វារីណា រៀបរាប់អំពីឯកសារដែលតម្កល់នៅបណ្ណាល័យ «សម្តេចម៉ែ»។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*យុវតី លេខ ការី មានតួនាទីជាអ្នកដើរតួនាទីជូនលោកជំទាវវេជ្ជបណ្ឌិត ដេវ៉្យានី ខុប្រាហ្គ្ដេ របស់ឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ទស្សនកិច្ចបណ្ណាល័យ «សម្តេចម៉ែ» ។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*





*យុវតី ហឿង ហ្គិច លីម មានតួនាទីជាអ្នកដើរតួនាទីជំនួសលោកជំទាវ ធីណា រ៉េដស របស់អង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ទស្សនកិច្ចបណ្ណាល័យ «សម្តេចម៉ែ»។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*លោកជំទាវ ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ វេជ្ជបណ្ឌិត ដេវីៗានី ខុប្រាហ្គីដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា កំពុងទស្សនាគំនូរដែលជាស្នាដៃរបស់វិចិត្រករ ញឹក ឌឹម នៅបណ្ណាល័យ «សម្តេចម៉ែ» ។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*លោកជំទាវ ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅបណ្ណាល័យ «សម្តេចម៉ែ» កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ដារ៉ារដ្ឋ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

**«ជាចុងក្រោយយើងបានរៀបចំគម្រោងមកទស្សកិច្ច នៅកន្លែងដ៏វិសេសវិសាលមួយនេះ។ អរគុណដែលបាននាំយើងដើរទស្សនាបណ្ណាល័យ «សម្តេចម៉ែ»។ អគារដ៏ស្រស់ស្អាត និងការងារដ៏មានសារសំខាន់។ ទាំងនេះគឺជាកិច្ចការងារដ៏ល្អប្រសើរនៃគំនិតផ្តួចផ្តើមរបស់ «ឯកអគ្គរដ្ឋទូតមួយថ្ងៃ»។**

— *លោកជំទាវ* **ធីណា រ៉េដស**

*ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា*



លោកជំទាវវេជ្ជបណ្ឌិត ដេវីយ៉ានី ខុប្រាហ្គីដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា មកទស្សនកិច្ចបណ្ណាល័យ «សម្តេចម៉ែ» កំពុងចារលើសៀវភៅត្រាំងមាស។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។
(ដារ៉ារដ្ឋ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

«អរគុណសម្រាប់ដំណើរទស្សនកិច្ចដ៏អស្ចារ្យ និងអាហារពេលព្រឹកដែលរៀបចំសម្រាប់ខ្ញុំ និងសម្រាប់ «ឯកអគ្គរដ្ឋទូតមួយថ្ងៃ» របស់ខ្ញុំក្នុងកិត្តិយសជាប្រវត្តិសាស្ត្រសម្រាប់ស្ត្រី នៅខែមីនា ឆ្នាំ២០២២។ ខ្ញុំសូមអរគុណដល់បណ្ណាល័យ «សម្តេចម៉ែ», ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ និង មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលសម្រេចបានការងារដ៏សំខាន់បំផុតក្នុងការថែរក្សាប្រវត្តិសាស្ត្រសម្រាប់យុវជន និង សហគមន៍។ សូមចូលរួមអបអរសាទរ និងការសម្រេចបាននូវស្នាដៃ និងការបង្កើតកន្លែងដ៏ស្រស់ស្អាតជាមួយសិល្បៈ គឺបណ្ណាល័យ «សម្តេចម៉ែ»។

— *លោកជំទាវវេជ្ជបណ្ឌិត* **ដេវយ៉ានី ខុប្រាហ្គីដេ**
*ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា*



គណៈប្រតិភូកំពុងស្តាប់លោកស្រី សូ ហ្វារីណា រៀបរាប់អំពីឯកសារដែលតម្កល់នៅបណ្ណាល័យ «សម្តេចម៉ែ»។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។
(ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# កិច្ចពិភាក្សារវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងអាជ្ញាធរស្រុកអង្គរធំ លើការងារគម្រោងសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*គីម សុវណ្ណដានី*



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាប្រជុំជាមួយអាជ្ញាធរស្រុកអង្គរធំ ខេត្តសៀមរាប។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងឧត្តមសេនីយ៍ត្រី និត ណារ៉ុង នាយសេនាធិការរង និងជាប្រធានក្រុមការងារប្រវត្តិសាស្ត្រយោធា យោធភូមិភាគទី៤ កងទ័ពជើងគោក កងយោធពលខេមរភូមិន្ទ រួមជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅជួបជាមួយលោក ថាន់ អាន់ អភិបាលរងស្រុកអង្គរធំ និងមេឃុំក្នុងស្រុកអង្គរធំជាច្រើនរូបដើម្បីជួបសំណេះសំណាល និងជម្រាបជូនព័ត៌មានទាក់ទងគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើង នូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ។

គោលបំណងនៃគម្រោងសុខភាពនេះ គឺ (១) ធ្វើឲ្យប្រសើរឡើង នូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទៅតាមគោលដៅដែលបានកំណត់ (២) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសម្រាប់អ្នករស់រានមាន ជីវិតពីរបបខ្មែរក្រហម និង (៣) ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេសនៅតាមសហគមន៍ដាច់ស្រយាលសម្រាប់ផ្តល់ជាព័ត៌មាន ក្នុងការរៀបចំជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់ប្រជាជននិងសហគមន៍ទាំងនេះ។

ចាប់តាំងពីដើមខែសីហា ឆ្នាំ២០២១មជ្ឈមណ្ឌលឯកសារកម្ពុជាបានជ្រើសរើសអ្នកស្ម័គ្រចិត្តកម្ពុជាបីជំនាន់រួចមកហើយ ដែលមានចំនួន៧០០នាក់ បាន

ចុះធ្វើការនៅតាមមូលដ្ឋានទូទាំង២៥ រាជធានីខេត្តក្រុងនៅក្នុងប្រទេសកម្ពុជា។ ក្នុងនោះមានអ្នកស្ម័គ្រចិត្តចំនួន១៥ នាក់មកពីស្រុកផ្សេងៗគ្នាក្នុងខេត្តសៀមរាប ត្រូវបានជ្រើសរើសឲ្យធ្វើការងារនៅក្នុងគម្រោងសុខភាពនេះ។ ក្រុមអ្នកស្ម័គ្រចិត្តនៅក្នុងខេត្តសៀមរាប បានចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាឪពុកម្តាយ អ៊ំពូ មីង ក៏ដូចជាអ្នកស្រុកភូមិរបស់ខ្លួន សរុបចំនួនប្រមាណ ៧០០ នាក់រួចមកហើយ។ នៅក្នុងខែមីនា ឆ្នាំ២០២២ នេះ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តជ្រើសរើស និងបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តជំនាន់ទីបួនមានចំនួនសរុបជាង ២០០នាក់មកពីបណ្តាខេត្តនានា នៅទូទាំងប្រទេសកម្ពុជា។ ចំពោះខេត្តសៀមរាប ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានកំណត់យកស្រុកអង្គរធំជាគោលដៅអទិភាពដើម្បីបន្តការងារ ព្រោះប្រជាជននៅក្នុងស្រុកនេះភាគច្រើនមានជីវភាពក្រីក្រ និងខ្វះខាត និងត្រូវការចាំបាច់នូវការថែទាំសុខភាព។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ លោកអភិបាលរងស្រុកអង្គរធំ លោក ថាន់ អាន់ និងក្រុមការងារបានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជ្រើសរើសយកស្រុកអង្គរធំជាគោលដៅដើម្បីចុះជួយដល់អ្នករស់រានរានមានជីវិតពីរបបខ្មែរក្រហម។




ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាប្រជុំជាមួយអាជ្ញាធរស្រុកអង្គរធំ ខេត្តសៀមរាប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជានិងអាជ្ញាធរស្រុកអង្គរធំ ខេត្តសៀមរាប ថតរូបជុំគ្នា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈន ខិន្នែត ៖ ខ្មែរក្រហមយកឪពុកខ្ញុំទៅសម្លាប់ដោយសារតែបណ្តោយឱ្យគោស៊ីកណ្តាប់

*សេង កញ្ញា និង ហេង ស្រីពេជ្រ*



ឈន ខិន្នែត អាយុ៥៨ឆ្នាំមានទីកន្លែងកំណើតនៅក្នុងភូមិត្រពាំងខ្វារ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឈន ខិន្នែត អាយុ៥៨ឆ្នាំ កើតនៅក្នុងភូមិត្រពាំងខ្វារ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត។ ខ្ញុំមានម្តាយឈ្មោះ ប៊ី សែ និងឪពុកឈ្មោះ ឈន សន (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតសរុបទាំងអស់ចំនួន ៦នាក់ (ស្លាប់២នាក់)។ កាលពីកុមារភាព ខ្ញុំរៀនបានតិចតួចណាស់ ដោយសារខ្ញុំខស្សរាហ៍ឈឺ និងមានការវាយប្រយុទ្ធគ្នារវាងកងទ័ព លន់ នល់ និងយោធាខ្មែរក្រហមដែលបង្កឲ្យមានចលាចលជាញឹកញាប់។

នៅក្នុងរបបខ្មែរក្រហមគ្រួសាររបស់ខ្ញុំការន់តែលំបាកខ្លាំង។ ឪពុករបស់ខ្ញុំគឺជាគ្រូបង្រៀន ដូច្នេះខ្មែរក្រហមបានចាត់ទុកគ្រួសារខ្ញុំគឺជាពួកមូលធន។ អង្គការបានបែងចែកគ្រួសាររបស់ខ្ញុំឲ្យទៅរស់នៅក្នុងភូមិថ្មីមួយទៀត។ ប្រជាជនដែលរស់នៅទីនោះអង្គការហៅថាជាពួកបញ្ញើ ឬប្រជាជនត្រៀម។ អង្គការបានចាត់តាំងឪពុករបស់ខ្ញុំឲ្យបររទេះដឹកកណ្តាប់ស្រូវ, ម្តាយរបស់ខ្ញុំប្រូតស្រូវ ហើយបងប្អូនរបស់ខ្ញុំ និងខ្ញុំដញ្ជូនកណ្តាប់ស្រូវ។ មានថ្ងៃមួយគោដែលឪពុករបស់ខ្ញុំយកទៅ ទឹមរទេះបានស៊ីកណ្តាប់ស្រូវ ខ្មែរក្រហមក៏យកឪពុកខ្ញុំទៅវាយសម្លាប់ចោល។

ដំបូង ខ្ញុំនិងម្តាយមិនដឹងថាខ្មែរក្រហមយកឪពុកខ្ញុំទៅសម្លាប់ទេ គឺមានអ៊ំប្រុសម្នាក់ដែលបររទេះដឹកកណ្តាប់ស្រូវជាមួយឪពុកខ្ញុំ បានឃើញខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំផ្ទាល់នឹងភ្នែក ហើយគាត់ក៏យកដំណឹងនេះមកប្រាប់គ្រួសារខ្ញុំ។ ក្រោយពេលដឹងថាឪពុករបស់ខ្ញុំស្លាប់ ម្តាយរបស់ខ្ញុំឈឺចិត្តយ៉ាងខ្លាំង ប៉ុន្តែគាត់មិនហ៊ានយំទេព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោលទៀត។ មានយប់មួយ ខ្ញុំនឹកឪពុកពេកក៏យំ ពេលនោះកងឈ្លបបានមកលបមើលបម្រុងយកខ្ញុំចេញទៅ ប៉ុន្តែខ្ញុំធ្វើពុតជាយល់សប្តិ។ ចំណែកបងស្រីរបស់ខ្ញុំ២នាក់ទៀតបានស្លាប់ដោយសារធ្វើការងារបាក់កម្លាំង និងហូបមិនគ្រប់គ្រាន់។ នៅពេលនោះ មានស្ត្រីពោះធំម្នាក់ចាញ់កូនក៏លួចបេះផ្លែឈើ

ហូប ប៉ុន្តែខ្មែរក្រហមបានតាមទាន់ក៏យកស្ត្រីនោះទៅវាយសម្លាប់ចោល។ ពេលខ្ញុំឃើញហេតុការណ៍នោះ ខ្ញុំភិតភ័យខ្លាំងណាស់។ ខ្ញុំមិនហ៊ាននិយាយពីហេតុការណ៍ដែលខ្ញុំបានឃើញទេ ព្រោះខ្ញុំភ័យខ្លាចខ្មែរក្រហមយកទៅសម្លាប់។ ខ្មែរក្រហមបានប្រើអ្នកទោសឲ្យជីករណ្តៅ នៅពេលជីករណ្តៅរួចហើយ ខ្មែរក្រហមវាយអ្នកទោសនោះទម្លាក់ចូលទៅក្នុងរណ្តៅ។ អ្នកទោសខ្លះមិនទាន់ស្លាប់ទេ ដូច្នេះខ្មែរក្រហមក៏កាយដីកប់ពីលើ។ ខ្ញុំមិនហ៊ានប្រកែក ប្តឹងតវ៉ាជាមួយខ្មែរក្រហមទេ ទោះបីខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំ, ប្រើខ្ញុំឲ្យធ្វើការងាររហូសកម្លាំង, មិនឲ្យហូបឆ្អែត និងមិនផ្តល់សម្លៀកបំពាក់ឲ្យខ្ញុំក៏ដោយ។ ក្រោយមកខ្មែរក្រហមបានប្រើខ្ញុំឲ្យបុកអង្ករដើម្បីត្រៀមធ្វើនំបញ្ចុកសម្រាប់ពិធីបុណ្យ ប៉ុន្តែពេលជិតដល់ថ្ងៃបុណ្យកងទ័ពវៀតណាមបានវាយចូលមកដល់។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានចូលរៀននៅសាលារហូតបានប្រឡងជាប់ជាគ្រូបង្រៀន។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ អ៊ុក សាវ៉ាត់ និងមានកូនប្រុស២នាក់។ ខ្ញុំប្រកបមុខរបរជាគ្រូបង្រៀនរហូតមកដល់បច្ចុប្បន្ន។



ឈន ខិន្នែត រួមជាមួយអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។
(ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទេសភាពវាលស្រែនៅរដូវប្រាំងក្នុងខេត្តតាកែវ។
(ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ថៃ ថាត ៖ ខ្មែរក្រហមសម្លាប់ក្រុមគ្រួសារខ្ញុំ ដោយសារតែលួចអាហារហូប

*មីន សាណាស់*



ថៃ ថាត អាយុ ៦២ឆ្នាំ រស់នៅភូមិជើងទឹក សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។
(មីន សាណាស់/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ថៃ ថាត អាយុ៦២ឆ្នាំ មានស្រុកកំណើតនៅភូមិសា ឡុង ឃុំក្តឿងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនបង្កើត៤នាក់ ប្រុសម្នាក់ (ស្លាប់ក្នុងសម័យខ្មែរក្រហម) និង ស្រីបីនាក់។ ឪពុករបស់ខ្ញុំឈ្មោះ ពោ ថៃ គឺជាកសិករ និងជាជាងកាត់សក់ ចំណែកម្តាយរបស់ខ្ញុំឈ្មោះ ស៊ុំ អៀត។ ឪពុកម្តាយរបស់ខ្ញុំស្លាប់នៅក្នុងសម័យខ្មែរក្រហម។

កាលពីកុមារភាព ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ ចាស់ ក្នុងសម័យសង្គមរាស្ត្រនិយម នៅសាលាស្វាយរមៀត ដែលមានទីតាំងនៅស្រុកកំណើតរបស់ខ្ញុំ។ លុះចូលដល់ឆ្នាំ១៩៧០ សាលាត្រូវបានបិទទ្វារដោយសារតែសង្គ្រាម។ ចំណែកគ្រូៗដែលធ្លាប់ជួលផ្ទះម្តាយរបស់ខ្ញុំស្នាក់នៅក៏សុំច្បាប់សាលាត្រឡប់ទៅរស់នៅស្រុកកំណើតរៀងៗខ្លួនដែរ។ នៅអំឡុងដើមឆ្នាំ១៩៧០ មានយុវជនបាននាំគ្នាចេញទៅធ្វើបាតុកម្ម ដោយយុវជននោះបានបែងចែកជាពីរក្រុមគឺ ក្រុមទី១) គាំទ្រ លន់ នល់ មកពីទីរួមខេត្តព្រៃវែង នាំគ្នាស្រែកថា «ជយោ សាធារណរដ្ឋ លន់ នល់» និង ក្រុមទី២) គាំទ្រសម្តេចព្រះ នរោត្តម សីហនុមកពីស្រុកអូររាំងឪ នាំគ្នាស្រែកថា «ជយោ សម្តេចតា»។ ក្រុមបាតុករទាំងពីរបានប៉ះទង្គិចគ្នាខ្លាំងនៅតំបន់ផ្សារពានា ឃុំក្តឿងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដែលបណ្តាលឲ្យបាត់បង់ជីវិតយុវជនអស់ជាច្រើននាក់។ ក្រោយពេលបាតុកម្មចប់ ភូមិរបស់ខ្ញុំក៏ធ្លាក់ចូលទៅក្នុងការកាន់កាប់របស់កងកម្លាំងរំដោះខ្មែរក្រហម និងមានការផ្លាស់ប្តូរអ្នកដឹកនាំនៅក្នុងភូមិដែរ។

នៅឆ្នាំ១៩៧៥ បន្ទាប់ពីយោធាខ្មែរក្រហមទទួលជ័យជម្នះលើរបប លន់ នល់ អ្នកគ្រប់គ្រងខ្មែរក្រហមប្រមូលទ្រព្យសម្បត្តិឯកជនទាំងអស់របស់ប្រជាជនដាក់ចូលក្នុងសហករណ៍រួម ហើយសូម្បីតែដំឡូងដុះនៅក្នុងបរិវេណផ្ទះរបស់ប្រជាជន ក៏ខ្មែរក្រហមហាមប្រជាជនមិនឲ្យដកយកមកហូបដែរ។ ចំពោះប្រជាជនណាដែលមាននិន្នាការប្រឆាំង ត្រូវបានអង្គការនាំយកទៅរៀនសូត្រ និងបាត់ខ្លួន។ ប្រជាជនក្នុងភូមិសា ឡុង

ត្រូវបានខ្មែរក្រហមជម្លៀសទៅនៅម្តុំមន្ទីរពេទ្យ៣-២ ជិតចម្ការកៅស៊ូពាមជាំង។ គ្រួសាររបស់ខ្ញុំត្រូវស្ថិតក្រោមការតាមដានរបស់ខ្មែរក្រហម ព្រោះខ្មែរក្រហមចោទគ្រួសារខ្ញុំថា ជាប់ខ្សែស្រឡាយវៀតណាម។ គ្រួសាររបស់ខ្ញុំបានធ្វើការធ្ងន់ធ្ងរជាងគ្រួសារផ្សេងទៀត ហើយអង្គការបម្រុងយកគ្រួសាររបស់ខ្ញុំទៅសម្លាប់ជាច្រើនលើកច្រើនសារ ប៉ុន្តែត្រូវបានឈ្លបភូមិជួយ។

ក្រោយមក ខ្មែរក្រហមបានកត់ឈ្មោះ និងបញ្ជូនក្រុមគ្រួសាររបស់ខ្ញុំឲ្យទៅរស់នៅតំបន់ដីខ្លាញ់ ដែលជាទីកន្លែងលត់ដំ។ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំឲ្យទៅនៅឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ។ នៅទីនោះ អង្គការបញ្ជាឲ្យខ្ញុំលីបាវស្រូវក្នុងមួយថ្ងៃឲ្យបាន១តោន យកទៅលាក់ទុកនៅឃ្លាំងធំមួយក្នុងព្រៃ។ ដោយឃើញខ្ញុំហត់ឡើយ បងប្រុសរបស់ខ្ញុំបានលួចមកជួយជញ្ជូនស្រូវ ប៉ុន្តែខ្មែរក្រហមដឹងក៏ចាប់បងប្រុសរបស់ខ្ញុំទៅសម្លាប់ចោល។ នៅអំឡុងពេលនោះ ឪពុករបស់ខ្ញុំពុំមានអាហារហូបគ្រប់គ្រាន់ឡើយ ដូច្នេះគាត់ក៏លួចកាប់ដំឡូងឈើនៅតាមផ្លូវដែលគាត់ដើរទៅធ្វើការយកមកហូប ក៏ត្រូវខ្មែរក្រហមឃើញ ហើយនាំគាត់យកទៅសម្លាប់ទៀត។ ក្រោយមក ដោយសារស្រេកឃ្លានខ្លាំងពេក ម្តាយរបស់ខ្ញុំបានលួចរើសគួរស្រូវយកមកបុក និងដាំបាយឲ្យកូនហូប ក៏ត្រូវឈ្លបខ្មែរក្រហមឃើញ ហើយរាយការណ៍ប្រាប់ប្រធានកងធំ។ យោធាខ្មែរក្រហមបានមកចាប់ម្តាយរបស់ខ្ញុំយកទៅសម្លាប់ចោលថែមទៀត។

នៅដើមខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានចូលមកផ្តួលរំលំរបបខ្មែរក្រហម។ ខ្ញុំនិងបងស្រីបានវិលត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែពេលមកដល់ភូមិ ផ្ទះនិងដីធ្លីរបស់ខ្ញុំត្រូវបានប្រជាជនបានចូលមករស់នៅមុនអស់ទៅហើយ។ ខ្ញុំនិងបងស្រីក៏បានសម្រេចចិត្តមករស់នៅចាប់ផ្តើមកសាងជីវិតសារជាថ្មីក្នុងភូមិជើងទឹក សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង រហូតមកដល់ពេលបច្ចុប្បន្ន។



រោងបាយរបស់អ្នកភូមិ ក្នុងស្រុកមេសាង ខេត្តព្រៃវែង។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ធឹក ង៉ែត៖ កូននារីស្រែអំបិល

ហៀក ស្រីពេជ្រ



ធឹក ង៉ែត អាយុ៦៥ឆ្នាំ រស់នៅភូមិស្រែពោធិ៍ ឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ កំពុងរៀបរាប់បទពិសោធន៍ជីវិតឆ្លងកាត់របបខ្មែរក្រហមទៅកាន់អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ធឹក ង៉ែត អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្រែពោធិ៍ឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីយោធាខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានធ្វើបាបមកលើខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំ ព្រោះដឹងថាបងប្រុសរបស់ខ្ញុំគឺជាអតីតជាទាហាន លន់ នល់ ចំណែកឪពុកម្តាយរបស់ខ្ញុំមានជីវភាពធូរធារកាលពីជំនាន់មុនៗ ខ្មែរក្រហមបានជម្លៀសប្រពន្ធកូនបងប្រុស

របស់ខ្ញុំ ដែលធ្លាប់ធ្វើទាហាន លន់ នល់ ទៅកាន់ខេត្តបាត់ដំបង។ ចំណែកខ្ញុំខ្មែរក្រហមបានបញ្ជូនឲ្យទៅធ្វើការងារវែកអំបិល។ ខ្ញុំតែងតែប្រុងប្រយ័ត្ននូវរាល់សកម្មភាពសព្វគ្រប់បែបយ៉ាង តាមដែលអាចធ្វើទៅបាន។ ខ្ញុំខិតខំធ្វើការងារជូនអង្គការមិនហ៊ានសម្រាកទេ សូម្បីតែពេលខ្ញុំឈឺ។ ខ្ញុំធ្វើការរហូតទាល់តែដួលសន្លប់នៅ ហ្នឹងកន្លែង ទើបប្រធានកងបញ្ជូនខ្ញុំទៅមន្ទីរពេទ្យ។ ខ្ញុំសម្រាកនៅពេទ្យបានពីរយប់ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យមកធ្វើការងារធម្មតាវិញ។ ខ្ញុំវែកអំបិលបីគោនក្នុងមួយថ្ងៃដោយសារ មានអ្នកខ្សឹបប្រាប់ខ្ញុំថាប្រសិនបើមិនខំប្រឹងធ្វើការងារទេប្រយ័ត្នអង្គការយកទៅសម្លាប់ចោល។ ក្រៅពីធ្វើការនៅស្រែអំបិល អង្គការបានចាត់តាំងខ្ញុំឲ្យឃ្វាលក្របី, វេញខ្សែគោ, ធ្វើបង្គីក្នុងមួយថ្ងៃឲ្យបាន១២គូរ និងបន្សាំគោ ស្ទូវចំនួន២៥នឹមដើម្បីភ្ជួរស្រែ។ គ្រប់ការងារដែលខ្មែរក្រហមបានដាក់ឲ្យ ខ្ញុំធ្វើបានទាំងអស់ដោយមិនហ៊ានប្រកែក ប្តូរ៉ាឡើយ ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោល។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំផ្លាស់មកធ្វើការងារដាកងដឹកជញ្ជូន ចំណែកការហូបចុក ខ្ញុំទទួលបានតែបបររាវដែលមានតែអង្ករមួយគ្រាប់ៗប៉ុណ្ណោះ។ ថ្ងៃខ្លះ ពេលដែលខ្ញុំចេញទៅឃ្វាលក្របី ខ្ញុំបានដើររើសត្នោតទុំយកមកហូបបន្ថែម។

រឿងរ៉ាវដែលខ្ញុំឈឺចាប់និងចងចាំមិនភ្លេចពីរបបខ្មែរក្រហមគឺ ខ្មែរក្រហមបានធ្វើទារុណកម្មនិងចាក់ថ្នាំសម្លាប់ឪពុករបស់ខ្ញុំ ដោយខ្មែរក្រហមចោទគាត់ថាគឺជាក្រុមមូលធនកាលពីជំនាន់មុន។ ចំណែក បងប្រុសរបស់ខ្ញុំនិងប្រពន្ធត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ដោយសារតែមានថ្ងៃមួយកូនរបស់ពួកគាត់ចង់ហូបត្រី ហើយពួកគាត់លួចចេញទៅរកត្រីឲ្យកូនហូបរហូតហួសម៉ោងធ្វើការ។ ខ្ញុំបានស្វែងរកក្តួយដែលកងនារីយកទៅចិញ្ចឹម ប៉ុន្តែខ្ញុំរកមិនឃើញ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានទៅនៅជំរំ ហើយឆ្លៀតចូលទៅសួររកក្តួយដែលបាត់ខ្លួននៅអង្គការកាកបាទក្រហមនៅជំរំ ប៉ុន្តែត្រូវបានអ្នកធ្វើការនៅទីនោះបដិសេធព្រោះខ្ញុំមកពីតំបន់ផ្សេង។




ធឹក ង៉ែត ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តតាកែវ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយមកខ្ញុំបានរៀបការ និងខិតខំរកប្រាក់។ ខ្ញុំបានត្រឡប់មកស្រុកកំណើតប្រកបរបរធ្វើស្រែរហូតមកដល់សព្វថ្ងៃ ប៉ុន្តែមិនសូវជាធូរធារប៉ុន្មានទេ។ ទោះបីយ៉ាងណាខ្ញុំរស់នៅប្រកបដោយភាពរីករាយនិងមានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការប្រកបការងារផ្សេងៗ។

# អ៊ាប ម៉ុង ៖ កងចល័តស្រុកព្រៃកប្បាស

**ប៉ាន់ ទីន**



អ្នកស្ម័គ្រចិត្តកម្ពុជាប្រគល់ប្រអប់អនុស្សាវរីយ៍ជូន អ៊ាប ម៉ុង។ (តាំង វិមន្ត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ាប ម៉ុង អាយុ៧៤ឆ្នាំ កើតនៅភូមិសំបត ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ សឹង ស៊ឹម និងម្តាយឈ្មោះ ភឿក វ៉ា។

នៅឆ្នាំ១៩៦៨ ខ្ញុំចូលរៀននៅសាលាព្រៃកប្បាស រយៈពេល៣ឆ្នាំ ក៏កើតមានរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ បន្ទាប់មក ខ្ញុំទៅរៀននៅវត្តអង្គរាញមួយរយៈខ្លី ក៏បួសជាព្រះសង្ឃ។ ខ្ញុំបួសបានរយៈពេលជិតមួយវស្សា ខ្មែរក្រហមឲ្យខ្ញុំសឹកវិញ។ នៅពេលខ្ញុំអាយុ១៥ឆ្នាំ ខ្ញុំបានចូលធ្វើការនៅកងចល័តឃុំព្រៃកប្បាស។ នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅជីកព្រែកនៅស្ទឹងព្រែកត្នោត ក្នុងខេត្តកំពង់ស្ពឺ រយៈពេល៣ខែ ទើបត្រឡប់មកភូមិ

វិញ។ ក្រោយមក ខ្មែរក្រហមបានបញ្ជូលខ្ញុំទៅនៅក្នុងកងចល័តស្រុកព្រៃកប្បាស និងចាត់តាំងឲ្យជីកព្រែក លើកប្រព័ន្ធភ្លឺស្រែ និងធ្វើស្រែ។ ខ្ញុំត្រូវធ្វើការ ទាំងយប់ទាំងថ្ងៃ និងបានសម្រាករយៈពេលមួយម៉ោងពេលហូបបាយនៅម៉ោង៥ល្ងាច។ បន្ទាប់មក នៅវេលាម៉ោង៦ល្ងាច ខ្មែរក្រហមប្រើខ្ញុំធ្វើការងារបន្តទៀត។ ខ្មែរក្រហមបានជម្លៀស ប្រជាជន១៧ មេសា មកធ្វើការជាមួយខ្ញុំ និងប្រើអ្នកទាំងនោះឲ្យធ្វើការងារគ្មានទំនេរឡើយ ចំណែកអាហារគឺមានតែបបររាវប៉ុណ្ណោះ។ ក្រុមគ្រួសារប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ ខ្មែរក្រហមបែងចែកឲ្យទៅនៅផ្ទះជាមួយអ្នកមូលដ្ឋាន ដែលក្នុងមួយផ្ទះមានអ្នកជម្លៀសចាប់ពី២ទៅ៣គ្រួសារ។ ប្រជាជនជម្លៀសមកថ្មីដែលប្រព្រឹត្តខុស គឺកម្មាភិបាលខ្មែរប្រហមបានយកអ្នកទាំងនោះទៅលត់ដំនៅជ្រៃអូរញ៉ោ ស្ថិតក្នុងខេត្តកំពង់ស្ពឺ។

ខ្ញុំធ្វើការទាំងឈឺ។ នៅរដូវប្រាំង ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យជីកព្រែក ហើយរដូវវស្សាខ្មែរក្រហមឲ្យខ្ញុំរែកកណ្ដាប់ ដកសំណាប ស្ទូង និងលើកប្រព័ន្ធភ្លឺស្រែ។ ប្រធានកងបានកំណត់ក្នុងម្នាក់ត្រូវលើកភ្លឺស្រែឲ្យបានប្រវែង៥ម៉ែត្រក្នុងមួយថ្ងៃ និងកំណត់ក្នុងមួយក្រុមដែលមានសមាជិកចំនួន១០នាក់ ត្រូវជីកព្រែកទទឹងប្រវែង៤ម៉ែត្របណ្ដោយ៥ម៉ែត្រ និងជម្រៅ១.៥ម៉ែត្រ។

ខ្ញុំធ្លាប់ឃើញខ្មែរក្រហមហៅក្រុមយុវជនឲ្យឡើងវេទិកាសេះ ដោយនិយាយប្រាប់យុវជនទាំងនោះថា «ឥឡូវអង្គការឲ្យប្អូនៗទៅស្រុកវិញហើយ គឺស្រុកនៅឯណាអង្គការឲ្យទៅទីនោះ»។ ពេលខ្លះខ្ញុំឃ្លានខ្លាំងពេកចង់លួចបេះផ្លែចេក និងល្ហុង យកមកហូប ប៉ុន្តែខ្ញុំខ្លាចឈ្លបខ្មែរក្រហមតាមទាន់។ សមាជិកកងខ្លះមិនបានហូបអាហារគ្រប់គ្រាន់ បណ្ដាលឲ្យខ្សោយហេវហត់និងដួលសន្លប់។ យើងបាននាំគ្នាសែងអ្នកជំងឺនោះទៅព្យាបាលនៅមន្ទីរពេទ្យស្រុកព្រៃកប្បាស។ យើងសែងអ្នកជំងឺនោះទៅដល់ពេទ្យ ម៉ោង១២ ឬម៉ោង១រសៀល ហើយពេលខ្លះពេទ្យក៏ជួយសង្គ្រោះបាន ពេលខ្លះក៏ជួយសង្គ្រោះអ្នកជំងឺនោះមិនបានដែរ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំបានរយៈពេល៤ខែ គឺនៅខែមេសា ឆ្នាំ១៩៧៩ ខ្ញុំបានរៀបការប្រពន្ធឈ្មោះស៊ីម សៀងលី និងមានកូនចំនួន ៤នាក់ គឺស្រី ៣នាក់ និងប្រុស១នាក់។



អ៊ាប ម៉ុង អាយុ៧៤ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅក្នុងភូមិអំពិលរៀង ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ កំពុងចែករំលែកបទពិសោធន៍ជីវិតរបស់គាត់នៅក្នុងសម័យខ្មែរក្រហម។
(តាំង វិមន្ត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឪពុករបស់ខ្ញុំស្លាប់ដោយសារលួចដំឡូង

***ចា៉ន់ ទីន***




*អ្នកស្ម័គ្រចិត្តកម្ពុជាប្រគល់ប្រអប់អនុស្សាវរីយ៍ជូន អ៊ុម អ៊ិន។ (ង៉ាន់ វីន / មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ អ៊ុម អ៊ិន មានស្រុកកំណើតនៅភូមិអំពិលរៀង ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ អ៊ុម អឿន និងម្ដាយឈ្មោះ ពេង ឡេង។ កាលនៅពីក្មេងខ្ញុំបានទៅរស់នៅជាមួយឪពុកម្ដាយនៅឯស្រុកអង្គរបុរី ខេត្តតាកែវ។ នៅពេលម្ដាយឪពុករបស់ខ្ញុំទៅធ្វើស្រែ ទុកឲ្យខ្ញុំនៅជាមួយបងៗ។ ខ្ញុំបានចូលរៀនត្រឹមថ្នាក់ទី៧ នៅសង្គមចាស់។ ដោយសារជីវភាពគ្រួសារលំបាក ទើបឪពុកខ្ញុំសម្រេចចិត្តយកខ្ញុំដែលពេលនោះមានអាយុ១៣ឆ្នាំឲ្យទៅរស់នៅជាមួយនឹងអ៊ំប្រុស ព្រោះតែខ្ញុំមិនអាចជួយការងារក្នុងបន្ទុកគ្រួសារដូចបងៗឯទៀត។ នៅអំឡុងពេលខ្ញុំរស់នៅជាមួយអ៊ំប្រុស ខ្ញុំនឹករឭកឪពុកម្ដាយខ្លាំងណាស់។ នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំបានរៀបការជាមួយប្រពន្ធឈ្មោះ ឈាន យ៉េង។

នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅជីកប្រឡាយ និងរែកដី នៅភ្នំអង្គរបូរី។ ប្រពន្ធរបស់ខ្ញុំ ខ្មែរក្រហមចាត់តាំងឲ្យស្ទូងស្រូវ និងធ្វើស្រែ។ ម្តាយរបស់ខ្ញុំ ខ្មែរក្រហមចាត់តាំងឲ្យដាំបាយ ហើយឪពុករបស់ខ្ញុំ អង្គការចាត់តាំងឲ្យឃ្វាលគោ និងក្របី។ អង្គការឲ្យយើងហូបតែបបរលាយជាមួយសម្លត្រកួនប៉ុណ្ណោះ។ ខ្ញុំមិនបានរស់នៅជួបជុំគ្រួសារទេ។ អង្គការបានបែងចែកមនុស្សឲ្យរស់នៅតាមកងផ្សេងៗគ្នា ដូចជា កងកុមារ កងយុវជន ចំណែកកងចាស់ៗ អង្គការចាត់តាំងឲ្យមើលក្មេងៗ។ ថ្ងៃមួយដោយសារឃ្លានខ្លាំងពេក ឪពុករបស់ខ្ញុំបានទៅលួចដំឡូងមកហូប ប៉ុន្តែកងឈ្លបតាមទាន់ក៏ចាប់ឪពុកខ្ញុំយកទៅវាយចោលនៅវាលស្រែ។ ដំបូងម្តាយរបស់ខ្ញុំបានដើររកឪពុករបស់ខ្ញុំ ប៉ុន្តែដើររកមិនឃើញទាល់តែសោះ។ ម្តាយរបស់ខ្ញុំទៅសួរអ្នកភូមិ ប៉ុន្តែគ្មាននរណាប្រាប់គាត់ឡើយ។ ម្តាយរបស់ខ្ញុំដើររកប្តីបណ្តើរ និងយំបណ្តើរ។ ក្រោយមកមានអ្នកភូមិម្នាក់បានលួចខ្សឹបប្រាប់ម្តាយរបស់ខ្ញុំថា ឪពុករបស់ខ្ញុំត្រូវបានអង្គការយកទៅវាយចោលនៅឯវាលស្រែហើយ។ ដោយសារអាណិតប្តីខ្លាំងពេក ម្តាយរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ ហើយក្រោយមកក៏បានស្លាប់។

បន្ទាប់ពីខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ខ្ញុំបានរស់នៅជុំជាមួយប្រពន្ធ និងកូនចំនួន៤នាក់ គឺស្រី១នាក់ ប្រុស៣នាក់។ បច្ចុប្បន្ន ខ្ញុំប្រកបមុខរបរធ្វើស្រែ និងរស់នៅក្នុងឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ ដដែល។



អ៊ុម អ៊ិន រស់នៅក្នុងភូមិអំពិលរៀង ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ កំពុងចែករំលែកបទពិសោធន៍ជីវិតរបស់គាត់នៅក្នុងសម័យខ្មែរក្រហម ប្រាប់ដល់អ្នកស័គ្រចិត្តកម្ពុជា ខេត្តតាកែវ។ (ង៉ាន់ វីន / មជ្ឈមណ្ឌលឯកសារកម្ពុជា)













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬអ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!















# តើលោកអាចកំណត់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដោយវិធីណា?

ឆាំង យុ





អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំបានបំផ្លាញមនុស្សធម៌របស់ប្រជាជន។ មជ្ឈមណ្ឌលឯកសារកម្ពុកមានគោលដៅស្តារឡើងវិញនូវអំពើមនុស្សធម៌នៃប្រជាជនទាំងអស់ មិនមែនត្រឹមតែជនរងគ្រោះតែប៉ុណ្ណោះទេ ប៉ុន្តែគឺរួមបញ្ចូលទាំងជនដែលបានប្រព្រឹត្តអំពើឃោរឃៅ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់ការគាំទ្រ និងសេវាកម្មដល់ប្រជាជនកម្ពុជាឲ្យច្រើនតាមអ្វីដែលអាចធ្វើបាន ដោយផ្អែកលើការជឿជាក់ថាប្រជាជនកម្ពុជាទាំងអស់ដែលធ្លាប់បានរស់នៅក្នុងរបបខ្មែរក្រហមទទួលការរងទុក្ខវេទនា។ បើនិយាយអំពីតួលេខ គឺមានអ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ចំនួន ៥,១៤៣,៣៨៦ នាក់ (អាយុ៥០ឆ្នាំ និងលើសពី៥០ឆ្នាំ) ស្មើនឹង ៣៣.១៦ ភាគរយនៃប្រជាជនសរុប ក្នុង១៩៦ស្រុក ក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៧។ មូលហេតុគឺ បច្ចុប្បន្ននេះប្រជាជនដែលមានអាយុចាប់ពី ៥០ឆ្នាំ ឬច្រើនជាង៥០ឆ្នាំ យ៉ាងហោចណាស់ជាក្មេងដែលមានអាយុ ៨ទៅ១០ឆ្នាំ នៅពេលដែលខ្មែរក្រហមដួល

រលំក្នុង១៩៧៩។ គាត់គឺជាក្រុមមនុស្សដែលនៅចងចាំរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម និងជាក្រុមមនុស្សដែលមានរឿងរ៉ាវសម្រាប់ចែករំលែកជាមួយយុវវ័យបច្ចុប្បន្ននេះ។

ទោះជាការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផ្ដោតសំខាន់លើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី ៥០ឆ្នាំ និងលើសពី ៥០ឆ្នាំ យ៉ាងណាក៏ដោយ យើងបានដឹងថានៅមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនទៀតដែលមានអាយុចាប់ពី៤០ឆ្នាំ និងលើសពី៤០ឆ្នាំ។ ដោយសារតែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ដែលមានអាយុចាប់ពី ៤០ឆ្នាំ គឺជាទារកនៅឡើយនៅពេលដែលរបបខ្មែរក្រហមត្រូវបានដួលរលំក្នុងឆ្នាំ១៩៧៩ យើងមិនរំពឹងថា គាត់នៅមានការចងចាំផ្ទាល់ណាមួយដែលចាំមិនភ្លេច និងអាចចែករំលែករឿងរ៉ាវរបស់គាត់ជាមួយយុវវ័យបច្ចុប្បន្ននេះបានទេ។ ទោះជានៅក្នុងកាលៈទេសៈដូចនេះយ៉ាងណាក្ដី មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្ដល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុ ៤០ឆ្នាំ និងលើសពី ៤០ឆ្នាំ ទាំងនោះក្នុងការពិនិត្យសុខភាពដូចអ្នកដទៃទៀតដែរ ប្រសិនបើគាត់មានបញ្ហាសុខភាពធ្ងន់ធ្ងរ។



អ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ស្វែងរកសមាជិកគ្រួសារ៦នាក់ ដែលបាត់ខ្លួនតាំងពីឆ្នាំ ១៩៧៣










ខ្ញុំសរសេរសេចក្តីប្រកាសនេះ ដើម្បីស្វែងរកក្រុមគ្រួសារ ខាងម្តាយក្មេករបស់ខ្ញុំ។ ម្តាយក្មេករបស់ខ្ញុំកើតនៅ ទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៥៦។ គាត់ត្រូវជាកូនស្រីរបស់ ប៉េង ខូវ ហៅ ខូយ (កើតឆ្នាំ១៩២១ និងស្លាប់ឆ្នាំ២០១៦) និងលីហ្គេតជួន (កើតឆ្នាំ១៩២០និងស្លាប់នៅឆ្នាំ២០១០)។ ម្តាយក្មេករបស់ខ្ញុំមានបងប្អូនបង្កើត១០នាក់ ហើយបងប្អូនរបស់គាត់ភាគច្រើនបានភៀសខ្លួនចេញពីប្រទេសកម្ពុជាតាមយន្តហោះក្នុងអំឡុងសង្គ្រាមឆ្នាំ១៩៧០ គឺនៅសល់តែបងស្រីធំម្នាក់ ដែលរៀបការរួច រស់នៅជាមួយប្តី និងកូន ៤ នាក់នៅក្នុងប្រទេសកម្ពុជា។ តាំងពីពេលនោះមក បងប្អូនប្រុសស្រីរបស់គាត់ទាំងអស់ដែលបានភៀសខ្លួនចេញពីប្រទេសកម្ពុជា ពុំដែលបានជួបបងស្រីធំទេ។ ឪពុកម្តាយរបស់គាត់ធ្លាប់បានស្វែងរកគាត់ដែរ ប៉ុន្តែឪពុកម្តាយរបស់គាត់ពុំដែលវិលត្រឡប់មកប្រទេសកម្ពុជាទេ ហើយបច្ចុប្បន្នពួកគាត់បានស្លាប់ទៅហើយ។

ម្តាយក្មេករបស់ខ្ញុំ និងបងប្អូនបង្កើតរបស់គាត់គ្រប់គ្នាសង្ឃឹមថា នឹងទទួលបានដំណឹងពីបងស្រីធំរបស់គាត់រួមជាមួយកូនៗនៅរស់រានមានជីវិត។

ខាងក្រោមនេះគឺជាឈ្មោះសមាជិកក្រុមគ្រួសាររបស់បងស្រីធំរបស់គាត់៖

- **ខូវ ខូយគិច** ឈ្មោះហៅក្រៅ **ឡ លីង** កើតឆ្នាំ១៩៥១ ត្រូវជាបងស្រីធំ
- **ឈូក សំអាន** កើតឆ្នាំ១៩៤៣ ត្រូវជាប្តីរបស់បងស្រីធំ

ខាងក្រោមនេះគឺឈ្មោះកូនទាំង៤នាក់របស់បងស្រីធំ៖

១) **ឈូក ថាវរិទ្ធ** កើតឆ្នាំ១៩៦៨
២) **ឈូក ខុនណ្ណារ័ត្ន** កើតឆ្នាំ១៩៦៩
៣) **ឈូក ថាវសុទ្ធ** កើតឆ្នាំ១៩៧០
៤) **ឈូក សេកហាម៉ូលី** កើតឆ្នាំ១៩៧៤

ប្រសិនបើបងប្អូនមានដំណឹងឬសំណួរអ្វី សូមផ្ញើអ៊ីម៉ែលមកកាន់ខ្ញុំ joaocsdocarmogil@gmail.com
សូមអរគុណ! ចៅ ស៊ូសា

# បងប្រុសរបស់ខ្ញុំដែលបាត់ខ្លួន



ហួន ស៊ីម និងប្អូនប្រុសឈ្មោះ ហួន ឆុន។
(អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ឆ្នាំង)



ម្តាយ និងឪពុករបស់ ហួន ស៊ីម ឈ្មោះ ពុត ស៊ិម និង អ៊ួ ផល
(អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ឆ្នាំង)

ខ្ញុំឈ្មោះ ហួន ស៊ីម ភេទស្រី អាយុ៥៥ឆ្នាំ រស់នៅភូមិត្បែង ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់គឺ៖ ទី១) ឈ្មោះ ហួន ដេន ២) ហួន ផល ៣) ហួន យុន ៤) ខ្ញុំ (ហួន ស៊ីម) និង ទី៥) ប្អូនប្រុសឈ្មោះ ហួន ឆុន។

ខ្ញុំគឺជាកូនស្រីតែម្នាក់គត់នៅក្នុងគ្រួសារ ដែលមានឪពុកឈ្មោះ អ៊ួ ផល និង ម្តាយ ឈ្មោះ ពុត ស៊ិម ។ នៅពេលដែលខ្មែរក្រហមកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅក្នុងឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ ម្តាយរបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យដាំបន្លែ និងធ្វើចុងភៅ ចំណែកឪពុកខ្ញុំដឹកជញ្ជូនអង្ករ។

ខ្ញុំមិនសូវចងចាំមុខមាត់បងប្រុសច្បាស់ទេ ប៉ុន្តែម្តាយខ្ញុំប្រាប់ថា បងប្រុស មានរូបរាងខ្ពស់ សម្បុរស និងមាឌធំ។ កាលពីឆ្នាំ១៩៧៥ ខ្ញុំមានអាយុប្រហែល៨ឆ្នាំ ខ្ញុំនៅចាំថាថ្ងៃមួយនៅកងកុមាររបស់បងប្រុសខ្ញុំ អង្គការបានចែកនំអាកោឲ្យម្នាក់មួយ ហើយបងប្រុសរបស់ខ្ញុំក៏ទទួលបានចំណែកមួយដែរ។ បងប្រុសរបស់ខ្ញុំមិនហ៊ានហូបខ្លួនឯងទេ គាត់ទុកចំណែករបស់គាត់ឲ្យមកខ្ញុំ។

ក្រោយមកបងប្រុសរបស់ខ្ញុំឈ្មោះ ហួន ដេន ត្រូវបានអង្គការចាត់តាំងឲ្យទៅរស់នៅកងកុមារដែលនៅឆ្ងាយពីកន្លែងខ្ញុំស្នាក់នៅ។ បន្ទាប់ពីគាត់ទៅរស់នៅកងកុមាររយៈពេល៣ខែ បងប្រុស ហួន ដេន ស្នើសុំអង្គការមកលេងផ្ទះ។ ពេលនោះគឺជាលើកចុងក្រោយដែល ខ្ញុំបានជួបគាត់។ ចាប់តាំងពីពេលនោះមក ខ្ញុំបាត់ដំណឹងរបស់គាត់សូន្យរហូតមកដល់សព្វថ្ងៃ។ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២២ ខ្ញុំបានជួបអ្នកស្ម័គ្រចិត្តកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយ ខ្ញុំផ្តល់ព័ត៌មាននេះដើម្បីប្រកាសស្វែងរកបងប្រុសរបស់ខ្ញុំ។

ខ្ញុំនៅតែចងចាំនិងនឹករឭកបងប្រុសរបស់ខ្ញុំជាពន់ពេក។ ប្រសិនបើមានបងប្អូនធ្លាប់ស្គាល់ឬមានព័ត៌មានប្រហាក់ប្រហែលនឹងការរៀបរាប់ខាងលើ សូមទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯសារកម្ពុជាដែលមានអាសយដ្ឋានផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេសាបាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬទំនាក់មកនាងខ្ញុំតាមរយៈទូរសព្ទលេខ ០៧១ ៨៨ ៦៥ ០៨៦ ឬ ០៧៨ ៦៩ ៨៣ ៣៣ ដោយក្តីអនុគ្រោះ។ សូមអរគុណ!

# ខ្ញុំសូមប្រកាសរកបងប្រុសដែលបាត់ខ្លួន



នូរ មករា ថតឆ្នាំ១៩៩៤។
(នូរ មករា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

នាងខ្ញុំឈ្មោះ **នូរ មករា** ហៅ មុំ ភេទស្រី មានអាយុ ៤៥ឆ្នាំ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិពោធិ៍តាគួយ ឃុំលលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ ខ្ញុំមិនចាំរូបរាងឪពុកម្តាយ និងបងប្រុសរបស់ខ្ញុំទេ ព្រោះកាលនោះ ខ្ញុំនៅជាកូនង៉ានៅឡើយ។

តាមរយៈឪពុកចិញ្ចឹមរបស់ខ្ញុំ ឈ្មោះ ពៅ វណ្ណ ហៅ ធី ដែលបានជួយសង្គ្រោះជីវិតខ្ញុំ និងបានយកខ្ញុំចេញពីសាកសពម្តាយរបស់ខ្ញុំបាននិយាយរៀបរាប់ប្រាប់ខ្ញុំថា នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ គាត់គឺជាទាហានប៉ារ៉ានៅដំរីតាមបណ្តោយព្រំដែនខ្មែរ-ថៃ និងតែងតែដើរល្បាតនៅក្នុងទឹកដីខ្មែរ។ ពេលដែលគាត់ធ្វើដំណើរដល់ឃុំក្តុលដូនទាវ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលជាទីកន្លែងសម្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហម គាត់និងទាហាន៥នាក់ទៀតនៅក្នុងអង្គភាពបានឮសំឡេងក្មេងយំ។ ដំបូងគាត់នឹកស្មានថាខ្មោចលង ប៉ុន្តែពេលគាត់ខិតខំផ្ទៀងស្តាប់ទើបដឹងថាសំឡេងក្មេងយំ។ នៅអំឡុងពេលនោះគាត់បានឃើញក្មេងប្រុសម្នាក់អាយុប្រមាណ៦ឆ្នាំ គឺជាបងប្រុសរបស់ខ្ញុំ កំពុងទាញខ្ញុំចេញពីសាកសពម្តាយដែលមានក្លិនស្អុយទៅហើយ ព្រោះពេលនោះខ្ញុំកំពុងបៅដោះម្តាយ។ បងប្រុសរបស់ខ្ញុំក្រឡេកក្រោយក៏ឃើញគាត់ (ឪពុកចិញ្ចឹមរបស់ខ្ញុំ)។ បងប្រុសរបស់ខ្ញុំស្មានថា គាត់គឺយោធាខ្មែរក្រហមក៏ទុកខ្ញុំចោល ហើយរត់គេចចេញទៅបាត់ ដោយមិនបានស្តាប់គាត់ស្រែកហៅឡើយ។ គាត់និងទាហាននៅក្នុងអង្គភាពបានឆែកសាកសពម្តាយរបស់ខ្ញុំរកឃើញឯកសារទាក់ទងនឹងឪពុកម្តាយបង្កើតរបស់ខ្ញុំ។ ឪពុកបង្កើតរបស់ខ្ញុំមានស្រុកកំណើតនៅទីក្រុងភ្នំពេញ ចំណែកម្តាយរបស់ខ្ញុំគឺជាអ្នកខេត្តបាត់ដំបង។ ឪពុករបស់ខ្ញុំជាប់សែស្រឡាយចិនមករស់នៅស្រុកខ្មែរ។ ឪពុករបស់ខ្ញុំមានរូបរាងខ្ពស់ សម្បុរស ចំណែកម្តាយរបស់ខ្ញុំទាប និងមានសម្បុរស្រអែម។

នៅអំឡុងឆ្នាំ១៩៨០ ពេលដែលខ្ញុំធ្វើដំណើរជាមួយឪពុកចិញ្ចឹមនៅតាមផ្លូវនៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មានស្ត្រីម្នាក់បានស្នើសុំខ្ញុំពីឪពុកចិញ្ចឹម យកទៅនៅជាមួយ។ ឪពុកចិញ្ចឹមខ្ញុំបានយល់ព្រមប្រគល់ខ្ញុំឲ្យស្ត្រីនោះ ព្រោះគាត់គិតថា គាត់មិនទាន់មានប្រពន្ធមិនអាចចិញ្ចឹមខ្ញុំបានឡើយ។

នៅក្នុងឆ្នាំ១៩៩៤ មានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរកើតលើម្តាយចិញ្ចឹមរបស់ខ្ញុំ។ ពេលនោះខ្ញុំបានជួបបុរសម្នាក់ដែលជាអ្នកបង្កហេតុបុកម្តាយចិញ្ចឹមរបស់ខ្ញុំបណ្តាលឲ្យមានរបួសចង្កេះ។ ម្តាយចិញ្ចឹមរបស់ខ្ញុំត្រូវបានបញ្ជូនមកមន្ទីរពេទ្យកាល់ម៉ែត្រដើម្បីព្យាបាល។ ខ្ញុំមិនចាំត្រកូល



នូវ មករា ថតឆ្នាំ២០២២។
( នូវ មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

របស់អ្នកបន្តហេតុច្បាស់លាស់ទេ គាត់ឈ្មោះ លី ប៊ុនធើន ឬ ឡុង ប៊ុនធើន។ គាត់បានសួរខ្ញុំថា «អ៊ំស្រីជាម្តាយបង្កើតរបស់ប្អូនឬ? ប៉ុន្តែមុខរបស់ប្អូនមិនដូចម្តាយរបស់ប្អូនទេ គឺមុខរបស់ប្អូនដូចបងទៅវិញ»។ ខ្ញុំមិនបានដឹងរឿងនេះទេ ព្រោះម្តាយចិញ្ចឹមរបស់ខ្ញុំមិនដែលប្រាប់ខ្ញុំ។ បង ប៊ុនធើន មានមុខមាត់ស្រដៀងខ្ញុំហើយគាត់ក៏បាត់ប្អូនស្រីដែរ។ គាត់បានប្រាប់ខ្ញុំថាប្រសិនបើមានកិច្ចការអ្វីអាចទៅរកគាត់បាន គាត់រស់នៅជាមួយម្តាយមីងនៅម្តុំផ្សារស៊ីលីបដោយប្រកបរបរលក់ដូរ និងលក់ដូង។ ក្រោយមក នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ទើបខ្ញុំដឹងថា ម្តាយដែលខ្ញុំរស់នៅជាមួយគឺជាម្តាយចិញ្ចឹម។ នៅក្នុងឆ្នាំ២០១៥ ខ្ញុំបានទៅរកបង ប៊ុនធើន នៅម្តុំផ្សារស៊ីលីបដើម្បីសួរនាំអំពីប្អូនស្រីរបស់គាត់ដែលបាត់ខ្លួនឲ្យច្បាស់ ព្រោះខ្ញុំក៏បាត់បងប្រុសដែរ ប៉ុន្តែប្រជាជនដែលរស់នៅម្តុំផ្សារស៊ីលីបប្រាប់ថា បងធើន បានលក់ផ្ទះហើយ។ បងធើន ធ្លាប់និយាយប្រាប់ខ្ញុំថា ប្រសិនបើគាត់រកប្អូនស្រីរបស់គាត់មិនឃើញទេ ពូរបស់គាត់នឹងនាំគាត់ទៅរស់នៅ ហុងកុង។

ខ្ញុំចង់ជួប បងធើន ដើម្បីសាកសួរព័ត៌មាន ហើយប្រសិនបើបងប្អូនណាដែលមានដំណើរជីវិតប្រហាក់ប្រហែលនឹងការរៀបរាប់ខាងលើអាចទំនាក់ទំនងមកនាងខ្ញុំតាមរយៈលេខទូរសព្ទ៖ ០៨៦ ៨២ ៧៥ ០៧ ឬ ០៩២ ៧១០ ៦០៨ ឬតាមរយៈសារអេឡិចត្រូនិច៖ truthmeta.d@dccam.org។ សូមអរគុណ!



នូវ មករា ថតឆ្នាំ២០២២។
(នូវ មករា / មជ្ឈមណ្ឌលឯកសារកម្ពុជា )

រូបក្របមុខ៖

រូបថត មេខលា កំពុងរាំលើផ្ទាំងថ្ម ស្ថិតនៅលើខ្នងភ្នំដងរែក ក្នុងស្រុកអន្លង់វែងតំណាងឲ្យសន្តិភាព ដែលមាននៅក្នុងបទចម្រៀងអន្លង់វែងស្នេហា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

រូបថតចាស់ៗដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្ដល់ឲ្យក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាពេលចុះទៅធ្វើការ នៅតាមតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 1st Quarter January-March 2022 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.